# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ គីម សាម៉េត ភេទប្រុស អាយុ៦២ឆ្នាំ

**ស្រុកកំណើតនៅភូមិក្របីព្រៃ ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ**

**រស់នៅភូមិព្រៃស្អាក ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**មុខងារសម័យខ្មែរក្រហមៈ កម្មករចម្ការកៅស៊ូ**

**ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០២:១២:១៨**

**៥០ទំព័រ**

ដានីៈ ដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំពេញ អ៊ំឈ្មោះអីដែរ?

សាម៉េតៈ ឈ្មោះ គីម សាម៉េត ។

ដានីៈ អ៊ំមានឈ្មោះអីក្រៅទៀតដែលអត់?

សាម៉េតៈ អត់ទេ ។

ដានីៈ ឈ្មោះអីចឹងតាំងពីដើមមក?

សាម៉េតៈ បាទ!

ដានីៈ អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

សាម៉េតៈ អាយុមែនទែន៦២ហើយ ។

ដានីៈ ចុះអាយុអ៊ំនេះប៉ុន្មានទៅ?

សាម៉េតៈ អាយុសំរាប់ធ្វើការងារ ។

ដានីៈ បាទ!

សាម៉េតៈ ដូចជា៥៨ ។

ដានីៈ ស្រុកកំណើតកើតជាអ៊ំនៅណាដែរ?

សាម៉េតៈ ខ្ញុំនៅ ភូមិហ្នឹងគេដូរឈ្មោះច្រើនពេកដូចលំបាកតាមដែរ ។

ដានីៈ ពីដើមមក?

សាម៉េតៈ ពីដើមឈ្មោះ ភូមិក្របីព្រៃ ដល់អីចឹងគេដូរតាមជំនាន់មួយៗ ។

ដានីៈ មកដល់ជំនាន់ឥឡូវគេដាក់ភូមិអីវិញ?

សាម៉េតៈ ខ្ញុំក៏អត់ច្បាស់ អត់សួរបានទៅដែរ តែពីដើមក្របីព្រៃ ។

ដានីៈ ឃុំអីដែរ?

សាម៉េតៈ ឃុំសំរោង ។

ដានីៈ ស្រុកអីគេនៅហ្នឹង?

សាម៉េតៈ ស្រុកត្រាំកក់ ។

ដានីៈ ខេត្តតាកែវ?

សាម៉េតៈ បាទ!

ដានីៈ គ្រួសារអ៊ំគាត់ឈ្មោះអីដែរ?

សាម៉េតៈ ខ្ញុំមានគ្រួសារ២ វាលំបាកប៉ុណ្ណឹងចុះ ។

ដានីៈ គ្រួសារមុន?

សាម៉េតៈ មុនហ្នឹងគាត់បែកបាក់គ្នាទៅ ក្រោយនេះ ។

ដានីៈ ក្រោយ?

សាម៉េតៈ ក្រោយឈ្មោះ ចេង ប៉ុល ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

សាម៉េតៈ ៥៣ ។

ដានីៈ អ៊ំមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

សាម៉េតៈ កូនច្រើន បើគិតទាំងសងខាងចូល១២នាក់ ។

ដានីៈ ទាំងអស់១២នាក់ ទាំងគ្រួសារមុន ទាំងគ្រួសារក្រោយ?

សាម៉េតៈ បាទ!

ដានីៈ ១២នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

សាម៉េតៈ ស្រី៤ ប្រុស៨ ។

ដានីៈ ពួកគាត់បានរៀនសូត្រដល់ថ្នាក់ណាខ្លះដែលទៅ?

សាម៉េតៈ ខ្ញុំពីមុននៅក្នុងសង្គមរាស្ត្រនិយម ខ្ញុំរៀនដល់ថ្នាក់ទី៤ ។

ដានីៈ អត់ទេ ខ្ញុំចង់ដឹងកូនៗសិន ។

សាម៉េតៈ កូនហ្នឹងក្តាប់អត់បានច្បាស់អស់ទេ ដោយឡែកច្បាស់តែកូននៅក្នុងបន្ទុកបច្ចុប្បន្ន ដែលខ្ញុំរស់នៅកន្លែងនេះទេ ។ កូនច្បងគេរៀនដល់ថ្នាក់ទី៨យើងបច្ចុប្បន្ន ហើយកូនមួយទៀតរៀនបានត្រឹមថ្នាក់ទី៦ ឯកូនស្រី២នាក់នោះ មួយរៀនបានថ្នាក់ទី៧ មួយរៀនបានដល់ថ្នាក់ទី១១ ។ ហើយកូនប្រុសបច្ចុប្បន្ននេះសល់ នៅក្នុងបន្ទុកគ្រួសារ៣នាក់ អាបន្ទាប់រៀនដល់ថ្នាក់ទី១២ប្រឡងជាប់បាក់ឌុបហើយ ដល់បន្ទាប់ពៅដល់ខ្ញុំកុនកំលាំងពលកម្ម ហើយវាសំរាកឃើញការលំបាករបស់ខ្ញុំ នៅពៅរៀនថ្នាក់ទី៩បច្ចុប្បន្ន ។

ដានីៈ អត់ទាន់បានរៀនចូលមហាវិទ្យាល័យទេ?

សាម៉េតៈ បេះតែចង់ហើយ តែពាក់ព័ន្ធនឹងជីវភាព ដល់អីចឹងឲ្យកូនទៅអត់រួច ក៏ឲ្យសំរាកសិន រង់ចាំឱកាសដោះស្រាយថវិការបាន ក៏បញ្ជូនកូនឲ្យទៅរៀន ។

ដានីៈ អ៊ំគិតថាចង់ដែរ បើសិនជាដោះស្រាយថវិការបាន បញ្ជូនឲ្យទៅរៀន ។

សាម៉េតៈ បញ្ជូនទៅរៀន ។

ដានីៈ ចង់ឲ្យកូនរៀនខាងអីទៅ?

សាម៉េតៈ ខ្ញុំអត់បានកំណត់ទេ តែវាសុំទៅរៀនផ្នែកខាងច្បាប់ ។

ដានីៈ គាត់ចូលចិត្តច្បាប់?

សាម៉េតៈ បាទ!

ដានីៈ ល្អដែរ បានទៅរៀនខ្ពស់ក៏ម្យ៉ាង ។ ហើយអ៊ំសព្វថ្ងៃនៅភូមិអីដែរ?

សាម៉េតៈ ខ្ញុំនៅភូមិព្រៃស្អាក ។

ដានីៈ ឃុំ?

សាម៉េតៈ ឃុំត្រពាំងប្រាសាទ ។

ដានីៈ ស្រុក?

សាម៉េតៈ ស្រុកត្រពាំងប្រាសាទ ។

ដានីៈ ខេត្តឧត្តរមានជ័យ?

សាម៉េតៈ បាទ!

ដានីៈ ឪពុកអ៊ំបង្កើតគាត់ឈ្មោះអីដែរ?

សាម៉េតៈ គីម សួង ។

ដានីៈ សព្វថ្ងៃគាត់នៅ?

សាម៉េតៈ ស្លាប់អស់ហើយ ។

ដានីៈ គាត់ខូចតាំងពីជំនាន់ណាទៅ?

សាម៉េតៈ ស្លាប់ជំនាន់យើងឥឡូវ គាត់ជរា គាត់អាយុ៧៩បានស្លាប់ ។

ដានីៈ ចុះម្ដាយ?

សាម៉េតៈ ម្ដាយ អុង ញ៉ៀន ។

ដានីៈ គាត់នៅឬក៏?

សាម៉េតៈ ស្លាប់ដែល គិតអាយុគាត់សុទ្ធតែចាស់ៗ ។

ដានីៈ គាត់ទើបតែស្លាប់ឥឡូវៗយើងហ្នឹង?

សាម៉េតៈ ឪពុកខ្ញុំស្លាប់ក្នុងអំឡុងយើងផ្សះផ្សារជាតិ ម្ដាយក៏ដូចគ្នា ។

ដានី៖ អ៊ំបងប្អូនបង្កើតប៉ុន្មាននាក់ដែរ ?

សាម៉េត៖ បងប្អូនបង្កើត៦នាក់ តែស្លាប់ក្នុងសង្គ្រាមអាមេរិកអស់២នាក់ ហើយនៅសល់តែខ្ញុំនិងប្អូនស្រី១នៅបាត់ដំបង ។

ដានី៖ ឥឡូវសល់តែ២នាក់ទេ?

សាម៉េត៖ នៅសល់៣នាក់ តែបងស្រីក៏រាងជរាដែលហើយ នៅសល់តែប្អូនស្រីខ្ញុំ ។

ដានី៖ ៦នាក់ហ្នឹង ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

សាម៉េត៖ ស្រី៣ ប្រុស៣ ។

ដានី៖ សព្វថ្ងៃសល់តែ៣នាក់ទេ?

សាម៉េត៖ ៣នាក់ហ្នឹង ម្នាក់នោះក៏អត់ទៀងទៀតតាមមើល ព្រោះនៅឆ្ងាយពីរនាក់ ។

ដានី៖ គាត់នៅបាត់ដំបងស្រុកណា?

សាម៉េត៖ ខ្ញុំអត់ច្បាស់ គ្រាន់តែដឹងថានៅជិតស្ពានអូរតាគី ។

ដានី៖ ប្រុសតែអ៊ំទេ?

សាម៉េត៖ បាទ! នៅតែខ្ញុំ ។

ដានី៖ ក្រៅពីហ្នឹងទៀតស្រី?

សាម៉េត៖ ២នាក់ទៀតស្រី ២នាក់ដែលប្រុសៗស្លាប់សម័យសង្គ្រាមឆ្នាំ១៩៧០ ។

ដានី៖ ស្លាប់២នាក់ដោយសារសង្គ្រាម?

សាម៉េត៖ បាទ!

ដានី៖ ពី៧០-៧៥ គាត់ធ្វើកងទ័ព?

សាម៉េត៖ បាទ!

ដានី៖ ហើយម្នាក់ទៀត?

សាម៉េត៖ ទ័ពទាំង៣នាក់ ទាំងខ្ញុំ ។

ដានី៖ ៣នាក់ទាំងអ៊ំ?

សាម៉េត៖ បាទ!

ដានី៖ ធ្វើកងទ័ពទាំង៣នាក់ ។ ដល់ពេលគាត់ស្លាប់តាំងពីមុនបែក៧៥ទៀត?

សាម៉េត៖ បាទ! ស្លាប់៧៣-៧៤ ។

ដានី៖ អ៊ំកូនទីប៉ុន្មានទៅ?

សាម៉េត៖ ខ្ញុំបើក្នុងបន្ទុកកូនទី៣ ។

ដានី៖ អ៊ីចឹងកាលពីក្មេងៗអ៊ំរៀនដល់ថ្នាក់ទី៨?

សាម៉េតៈ បាទ!

ដានីៈ ទី៨ពីសង្គម?

សាម៉េតៈ បាទ!

ដានីៈ រៀននៅវត្តណាទៅ? ប្រលំរៀននៅសាលាណា?

សាម៉េតៈ នៅវិទ្យាល័យកូនចៅសម្តេចឪអង្គតាសោម ។

ដានីៈ ឆ្នាំណាបានឈប់ហ្នឹង?

សាម៉េតៈ ឆ្នាំរដ្ឋប្រហារ ។

ដានីៈ រដ្ឋប្រហារឈប់តែម្តង?

សាម៉េតៈ បាទ!

ដានីៈ កាលហ្នឹងអ៊ំរៀនដល់ថ្នាក់ទី៨ហើយ?

សាម៉េតៈ បាទ!

ដានីៈ កាលហ្នឹងអ៊ំមានបំណងចង់ឲ្យរៀនដល់ណា? ចង់ធ្វើអីដែរកាលពីក្មេង? បំណងប្រាថ្នាយើងកាលពីក្មេង?

សាម៉េតៈ កាលជំនាន់នោះគឺថា បើសិនស្រុកកុំកើតសង្គ្រាម បើសិនឪពុកម្តាយមានធនធានឲ្យរៀន រៀនទាល់តែណាណឹតែម្តង ប្រើពាក្យខ្មែរយើងថាណាណឹ ពីព្រោះខ្ញុំមិនដឹងអារម្មណ៍យ៉ាងណាទេ ក្រោយពីផ្សះផ្សារជាតិហើយខ្ញុំទៅរៀននៅសាលាភូមិន្ទរដ្ឋបាល តែដល់ហើយមើលទៅចាស់ហើយ ខ្វះទុន ឥឡូវហ្នឹងចំណាស់ហ្នឹងក៏នឹកឃើញចង់ទៅរៀនតទៅទៀត តែពាក់ព័ន្ធនឹងនៅជីវភាព ។

ដានីៈ តែបំណងប្រាថ្នាអ៊ំ អ៊ំគិតថាចង់រៀនឲ្យបានច្រើន ចង់ធ្វើអីវិញទៅ?

សាម៉េតៈ កាលហ្នឹងមិនទាន់មានទិសដៅយ៉ាងណាទេ គ្រាន់តែចង់រៀនឲ្យចេះ ចេះសំខាន់យល់ដឹងពីបញ្ហានូវការវិវត្តន៍ប្រទេសយ៉ាងណាៗ ។

ដានីៈ អត់ចង់ចាប់យកជំនាញអ្វីទេកាលនោះ?

សាម៉េតៈ ជំនាន់កាលហ្នឹងមិនទាន់ដឹងថាទៅខាងណាៗ សំខាន់ឲ្យចេះសិន ។

ដានីៈ អីចឹងដល់ពេលរដ្ឋប្រហារហើយ អ៊ំឈប់ឬយ៉ាងម៉េចពេលហ្នឹង?

សាម៉េតៈ រដ្ឋប្រហារហើយមានចលនាតស៊ូហ្នឹងក៏ចាប់ផ្តើមចូលជាមួយគេ ។

ដានីៈ ចូលខែណាទៅ រដ្ឋប្រហារឆ្នាំ៧០ ខែ៣?

សាម៉េតៈ រដ្ឋប្រហារហើយខ្ញុំចូលធ្វើជាកងទ័ពតាំងពីឆ្នាំ១៩៧០ តាមខ្ញុំចាំខែ៤-៥ ។

ដានីៈ កាលហ្នឹងអ៊ំស្ម័គ្រចិត្តចូល ឬក៏មានគំនាបអី?

សាម៉េតៈ ស្ម័គ្រចិត្តចូល ។

ដានីៈ អ៊ំអាចនៅចាំទេថាយើងស្ម័គ្រចិត្តចូលជាមួយកងណា? ចូលធ្វើអី? ហើយទៅកន្លែងណាៗ?

សាម៉េតៈ នៅចាំតិចតួចណាស់ ។ កាលជំនាន់ហ្នឹងខ្ញុំនៅធ្វើកងទ័ពស្រុកតែម្តង ។

ដានីៈ កងទ័ពស្រុកត្រាំកក់?

សាម៉េតៈ បាទ! ដល់ហើយចេះតែវិវត្តន៍ប្រែប្រួលម្តងមកភូមិ ម្តងមកឃុំ ម្តងទៅទ័ព គេចល័តជាប់

ដានីៈ គេចល័តម្តងធ្វើកងទ័ព ម្តងមកនៅខាងគ្រប់គ្រងនៅតាមភូមិ-ឃុំវិញ?

សាម៉េតៈ បាទ! ក៏ទៅកងទ័ព ដល់អីចឹងពិបាកចាំខែ ពិបាកចាំថ្ងៃ ។

ដានីៈ ដល់ពេល៧១-៧២-៧៣ យ៉ាងម៉េចវិញ ។

សាម៉េតៈ ៧១មកធ្វើការនៅខាងតាមភូមិ ។

ដានីៈ នៅភូមិណាទៅ?

សាម៉េតៈ ភូមិដែលខ្ញុំបានជំរាប ។

ដានីៈ ភូមិក្របីព្រៃ?

សាម៉េតៈ បាទ!

ដានីៈ ធ្វើយូរទៅនៅភូមិ?

សាម៉េតៈ អត់យូរទេ ប្រហែលកន្លះឆ្នាំ ។

ដានីៈ ដូចថាគេបញ្ជូនពីកងទ័ពឲ្យមកគ្រប់គ្រងប្រជាជននៅភូមិវិញ?

សាម៉េតៈ បាទ! ហើយក៏ទៅធ្វើការនៅឃុំ បកពីឃុំទៅកងទ័ព សារចុះ សារឡើង ។

ដានីៈ ចេញពីភូមិមកឃុំ?

សាម៉េតៈ បាន២-៣ខែ គេរុញទៅសមរភូមិវិញ ។

ដានីៈ កាលហ្នឹងគេខ្វះមនុស្សឬយ៉ាងម៉េច?

សាម៉េតៈ បាទ!

ដានីៈ ដូចថាអីចឹងទៅគេឲ្យគ្រប់គ្រងភូមិមួយរយៈ ឲ្យមកគ្រប់គ្រងនៅសំរោងមួយរយៈទៀត គេបញ្ជូនទៅកងទ័ពវិញ?

សាម៉េតៈ បាទ!

ដានីៈ ប្រហែលជាឆ្នាំប៉ុន្មានដែលបញ្ជូនទៅកងទ័ពវិញ?

សាម៉េតៈ កាលហ្នឹងវៃខ្ញាំង ខ្ញុំដូចជាអត់ចាំ ដូចជា៧៣ ។

ដានីៈ ចូលមកកងទ័ពនៅណាវិញទៅ?

សាម៉េត៖ មកកងទ័ពស្រុកវិញ ។

ដានី៖ តែអ៊ំមកកងទ័ពស្រុក យើងទទួលជាអ្នកគ្រប់គ្រងនៅកងទ័ពស្រុក?

សាម៉េត៖ ជាអនុសេនាធំ យើងភាសាកាលនោះ ។

ដានី៖ កងទ័ពច្រើនទេអនុសេនាធំ?

សាម៉េត៖ កាលហ្នឹងពេញ១២០នាក់ ។

ដានី៖ ច្រើនដែរ?

សាម៉េត៖ បាទ!

ដានី៖ ហើយយើងកងទ័ពស្រុកវៃនៅណាទៅ?

សាម៉េត៖ កាលហ្នឹងវៃនៅវិហារខ្ពស់ ។

ដានី៖ វិហារខ្ពស់ម្តុំណាខ្ញុំអត់ស្គាល់?

សាម៉េត៖ ម្តុំជុំវិញតាកែវ ។

ដានី៖ បាទ! វៃម្តុំតាកែវ ។

សាម៉េត៖ ហើយផាកមកស្វាយព្រៃ អាហ្នឹងនៅប្រទល់ប្រទាញគ្នា ពេលខ្លះយើងក៏ទៅវៃនៅម្តុំវិហារខ្ពស់ ម្តុំគេហៅថាវត្តឈើទាល វៃម្តុំផ្លូវរទេះភ្លើង ។

ដានី៖ វៃរហូតដល់ពេលណាទៅបានឈប់?

សាម៉េត៖ មកដល់ឆ្នាំ៧៥ ។

ដានី៖ អ៊ីចឹងចន្លោះពី៧៣-៧៥ អ៊ំវៃនៅជុំវិញតាកែវរហូត?

សាម៉េត៖ បាទ! ជុំវិញតាកែវ ។

ដានី៖ វៃរហូតដល់យើងបានជ័យជំនះលើ លន់ នល់?

សាម៉េត៖ បាទ!

ដានី៖ ដល់ពេលបានជ័យជំនះលើលន់ នល់ ឆ្នាំ៧៥ហើយ អ៊ំយ៉ាងម៉េចទៀត? នៅស្រុកដដែលឬមានការផ្លាស់ប្តូរទៅណា?

សាម៉េត៖ ផ្លាស់ប្តូរមកខាងភូមិភាគខគ្គរ ។

ដានី៖ មកភូមិភាគខគ្គរ?

សាម៉េត៖ បាទ!

ដានី៖ ឆ្នាំណាដែលអ៊ំមកភូមិភាគខគ្គរ?

សាម៉េត៖ ចាំអត់ច្បាស់ដែរ ។

ដានី៖ ខែ៨ ឆ្នាំ៧៩ យើងបែក យើងរំដោះបានទូទាំងប្រទេស ទទួលបានជ័យជំនះ អ៊ំនៅស្រុកមួយរយៈសិន ឬគេផ្លាស់មកខត្តរ?

សាម៉េត៖ នៅស្រុកមួយរយៈដែរ ។

ដានី៖ អ៊ំនៅស្រុកណាដែរ?

សាម៉េត៖ នៅស្រុកដដែល ។

ដានី៖ នៅស្រុកត្រាំកក់ហ្នឹង?

សាម៉េត៖ បាទ!

ដានី៖ ដល់ពេលហ្នឹងអ៊ំនៅជាកងទ័ព ឬយើងមកខាងគ្រប់គ្រងប្រជាជន?

សាម៉េត៖ គេឲ្យទៅនៅការពារតាមភ្នំ ភ្នំខាងក្រោយ ។

ដានី៖ ខាងជីរមៀល?

សាម៉េត៖ បាទ! ឲ្យរៀបចំកងការពារព្រៃភ្នំហ្នឹងផង ធ្វើស្រែចំការផង ។

ដានី៖ កាលហ្នឹងកងទ័ពគ្រាន់តែការពារ តែយើងធ្វើស្រែ ចំការផ្គត់ផ្គង់អង្គភាពខ្លួនយើង ។

សាម៉េត៖ សល់ជួយប្រជាពលរដ្ឋ ។

ដានី៖ ជាអង្គភាពយោធាស្រុកត្រាំកក់ ឬក៏ជាតំបន់កាលនោះ?

សាម៉េត៖ ស្រុក ។

ដានី៖ ស្រុកត្រាំកក់?

សាម៉េត៖ បាទ!

ដានី៖ កាលហ្នឹងគ្នាច្រើន?

សាម៉េត៖ នៅច្រើន ។

ដានី៖ នៅបានប៉ុន្មានបានគេផ្លាស់អ៊ំខាងខត្តរ?

សាម៉េត៖ ខ្ញុំអត់ចាំច្បាស់ តែពេលដូចជាមានបញ្ហាតាមព្រំដែនយើង វៀតណាមហើយ ដកមកខាង

ដានី៖ ៧៦-៧៧?

សាម៉េត៖ បាទ! ខ្ញុំប៉ុណ្ណឹងតាមមើល តាមយើងសន្និដ្ឋាន ព្រោះកាលហ្នឹងអត់បានធ្វើកំណត់ហេតុអីច្បាស់លាស់ទេ ។

ដានី៖ ប្រហែលជា៧៦ឬ៧៧តាមអ៊ំគិត?

សាម៉េត៖ សុំទោសខ្ញុំចង់សួរបក កើតបញ្ហាតាមព្រំដែនមិនដឹងជាឆ្នាំប៉ុន្មាន?

ដានី៖ ព្រំដែននៅណា?

សាម៉េត៖ កម្ពុជា-វៀតណាម?

ដានី:　យើងចាប់ផ្ដើម៧៧ ។

សាម៉េត: អាចខ្លះប៉ុណ្ណឹង ។

ដានី: យើងចាប់ផ្ដើមមានសង្គ្រាមជាមួយគ្នា ប្រហែល៧៧?

សាម៉េត: បាទ!

ដានី: អ៊ំផ្លាស់ពីត្រាំកក់ មកខគ្គរនៅណាវិញទៅ?

សាម៉េត: ខ្ញុំនៅចំការកៅស៊ូ ជាកម្មករចំការកៅស៊ូ ។

ដានី: មកខាងកម្មករចំការកៅស៊ូខាងកំពង់ចាម តែវាមានច្រើនកន្លែង ។

សាម៉េត: មកប៉ែកខាងចំការលើ ។

ដានី: ខាងចំការលើ ចំការអណ្ដូងហើយអ៊ីចឹង ។

សាម៉េត: បាទ!

ដានី: ពីព្រោះនៅកំពង់ចាមមាន២ បើយើងឆ្លងទន្លេទៅខាងនោះ តែពីជំនាន់មុនខ្ញុំអត់ដឹងទេ ចំការកៅស៊ូកំពង់ចាមមានខាងចំការកៅស៊ូចំការអណ្ដូង, ចំការកៅស៊ូបឹងកេត, ចំការកៅស៊ូជប់, ក្រែក និងមេមត់ ។

សាម៉េត: ខាងកើតទន្លេ ។

ដានី: ខាងលិចទន្លេ ខាងកើតទន្លេ?

សាម៉េត: និយាយខាងកើត វាខាងកើទន្លេ ។

ដានី: ខាងកើតទន្លេភូមិភាគបូព៌ា បើខាងលិចទន្លេរបស់ភូមិភាគខគ្គរ ឬភូមិភាគកណ្ដាល ។

សាម៉េត: បាទ!

ដានី: អ៊ីចឹងក្នុងឆ្នាំ៧៧ហ្នឹងអ៊ំមកខាងចំការអណ្ដូង អ៊ំមកទទួលអីវិញទៅចំការអណ្ដូង?

សាម៉េត: ទទួលកម្មករសហជីពមួយ ។

ដានី: គ្នាប្រហែលប៉ុន្មាននាក់ទៅ?

សាម៉េត: កម្មករសហជីពប្រហែលជាបើគិតជាគ្រួសារ ដូចភូមិយើងប្រហែល៣០០គ្រួសារ ។

ដានី: ខ្ញុំនឹកឃើញហើយកាលភូមិភាគខគ្គរមុនគេមានក្រុមរបស់គេផ្សេង អ្នកគ្រប់គ្រងពីមុនមកដល់ពេលក្រោយមកមានគេជំរុះ ឬគេចាប់បញ្ជូនទៅ ពួកអ៊ំមកជំនួសថ្មីៗ?

សាម៉េត: បាទ!

ដានី: កាលហ្នឹងអ៊ំលឺព័ត៌មានហ្នឹងដែរ?

សាម៉េត: ព័ត៌មានយ៉ាងម៉េច ។

ដានី: ព័ត៌មានដូចថាមុននឹងគេបញ្ជូនអ៊ំមកខគ្គរគេមានប្រាប់ថាខាងអ្នកដឹកនាំចាស់?

សាម៉េតៈ	អត់ទេ គេបញ្ជូនមកដល់គេគ្រាន់តែប្រាប់ថាចូលទៅនេះទៅ គ្រប់គ្រង ។

ដានីៈ	កាលហ្នឹងពីណាគេទទួលរូមនៅចំការអណ្តូង?

សាម៉េតៈ	ច្រើនផ្នែកណាស់ ច្រើនគ្នា ។ មិនដឹងជាស្លាប់ប្ញុរស់ គាត់នៅប៉ៃលិន ។

ដានីៈ	ពីណាគេ?

សាម៉េតៈ	ជន មិនដឹងនាមត្រកូលគាត់អី ពីដើមអត់ដែលប្រើនាមត្រកូលទេ ប្រើឈ្មោះខ្លីៗ ។

ដានីៈ	តាជន?

សាម៉េតៈ	បាទ!

ដានីៈ	ខ្ញុំស្គាល់កូនគាត់ ។

សាម៉េតៈ	អីចឹង!

ដានីៈ	កូនគាត់ លី, ឡា?

សាម៉េតៈ	ប្រពន្ធគាត់ឈ្មោះ ឡាវ ។

ដានីៈ	បាទ! តែកូនគាត់ឈ្មោះលី ឈ្មោះឡា ។ លី ប្តីគាត់ឈ្មោះធូ ប្អូនរបស់ស៊ូ មេត?

សាម៉េតៈ	ប្រហែលហ្នឹង ។

ដានីៈ	គាត់នៅសំឡូត ។

សាម៉េតៈ	ហ្នឹងហើយ ។

ដានីៈ	គាត់ស្គាល់គាត់ ធ្លាប់រាប់អានគ្នាដែរ ។ អីចឹងជន ហ្នឹងគាត់ទទួលរូមនៅចំការអណ្តូង?

សាម៉េតៈ	ហ្នឹងហើយ ។

ដានីៈ	ដល់ពេលអីបន្ទាប់ៗពីគាត់មក?

សាម៉េតៈ	អត់ទេ គាត់មេរូម ខ្ញុំនៅតាមសហជីព ដូចភូមិ ឃុំអីចឹង ។

ដានីៈ	អីចឹងចំការកៅស៊ូគ្នាច្រើន?

សាម៉េតៈ	ច្រើនណាស់ រាប់ម៉ឺននាក់ ។

ដានីៈ	ចំការកៅស៊ូអត់មានចំណុះឲ្យតំបន់?

សាម៉េតៈ	អត់ទេ ។

ដានីៈ	នៅដាច់ពីតំបន់?

សាម៉េតៈ	នៅដាច់ពីតំបន់ចូលខាងទំនាក់ទំនងជាមួយភូមិភាគតែម្តង ភូមិភាគហើយឡើង ឧបមាថា សម្ភារៈផ្គត់ផ្គង់ជាប្រេង ជារថយន្តសំរាប់ដឹកជញ្ជូន ជាខោអាវស្បៀកពាក់អីផ្សេងៗដឹកពីភ្នំពេញមក ។

ដានីៈ	អីចឹងចំការកៅស៊ូដូចស្វ័យត?

សាម៉េត៖ បាទ! ស្វាយ័ត ។

ដានី៖ កាលហ្នឹងភូមិភាគគេហៅភូមិភាគឧត្តរ ឬភូមិភាគកណ្តាល?

សាម៉េត៖ តាមខ្ញុំចាំមកដំបូងគេហៅភូមិភាគឧត្តរ រួចបែងចែកមកខាងប៉ែកខាងសៀមរាប ស្ទើមួយទៀតទេ ។

ដានី៖ សៀមរាប-ឧត្តរមានជ័យ?

សាម៉េត៖ ហ្នឹងហើយ ប៉ែកខាងសៀមរាបគេហៅឧត្តរម្តង ។

ដានី៖ ដល់កន្លែងអ៊ំទៅគេដូរជា ។

សាម៉េត៖ ជាភូមិភាគកណ្តាល ។

ដានី៖ កាលហ្នឹងតាកែ ពក គាត់នៅជាភូមិភាគ ឬពីណាគេ?

សាម៉េត៖ កាលហ្នឹងអ៊ំពក គាត់នៅ ។

ដានី៖ អ៊ំពក គាត់ទទួលរួម?

សាម៉េត៖ ទទួលរួម ។

ដានី៖ ពីណាបន្តបន្ទាប់គាត់?

សាម៉េត៖ អត់សូវច្បាស់ទេកាលហ្នឹង ព្រោះកាលហ្នឹងគេមិនសូវឲ្យ ហើយយើងទទួលការងារថ្នាក់ក្រោមដល់អីចឹងខ្ញុំអត់សូវយល់ ។

ដានី៖ មានប៉ុន្មានតំបន់ដែរកាលហ្នឹង កាលពីអ៊ំទៅ?

សាម៉េត៖ អត់សូវច្បាស់អស់ទេខ្ញុំ ព្រោះវាហាក់ដូចជា ដូចអូនមានប្រសាសន៍ថាវាជាកន្លែស្វយ័តដល់យើងពាក់ព័ន្ធនឹងខាងមូលដ្ឋានអត់សូវស្គាល់ទេ ។

ដានី៖ ខាងមូលដ្ឋានអត់នេះទេ?

សាម៉េត៖ បាទ! ព្រោះនិយាយលេងទៅ ព្រលឹមឡើងគឺថាម៉ោង៨កន្លះ ឬម៉ោង៩ចូលទៅឡូកៅស៊ូម៉ោង១២សារជ័រមកចូលមកផ្ទះវិញ អត់មានពេលដូចនៅតាមភូមិ តាមឃុំទេ ដល់អីចឹងការទំនាក់ទំនងគ្នាវាអត់ដឹងច្បាស់ថាយ៉ាងណាៗ ។

ដានី៖ កាលហ្នឹងអ៊ំមានគ្រួសារនៅ?

សាម៉េត៖ គ្រួសារមុន ។

ដានី៖ គ្រួសារមុនអ៊ំរៀបការតាំងពីអង្គាល់?

សាម៉េត៖ ដូចជា៧៤-៧៥ មិនដឹងខ្ញុំអត់ច្បាស់ដែរ ។

ដានី៖ ៧៤-៧៥ មុនបែកទីក្រុងភ្នំពេញទៀត?

សាម៉េត៖ បាទ! មុន ។

ដានី: ហើយកាលហ្នឹងអ៊ំមានកូនចៅហើយ?

សាម៉េត: មាន ។

ដានី: មានប៉ុន្មាននាក់?

សាម៉េត: មាន៣នាក់ ។

ដានី: ហើយដល់ពេលមកកំពង់ចាមមកទាំងអស់គ្នា?

សាម៉េត: បាទ! មកទាំងអស់គ្នា ។

ដានី: អ៊ំនៅចំការអណ្ដូងហ្នឹងរហូត ឬមានការផ្លាស់ប្ដូរទៅណាទៀត?

សាម៉េត: អត់ទេ ខ្ញុំនៅហ្នឹងរហូត ។

ដានី: នៅរហូតដល់បែក?

សាម៉េត: បាទ!

ដានី: កាលហ្នឹងអ៊ំមានដែលឆ្លងទៅខាងបូព៌ាទេ?

សាម៉េត: អត់ដែលស្គាល់រហូតដល់ឥឡូវក៏អត់ដែលស្គាល់ ។

ដានី: អត់ដែលឆ្លងសាឡាងទន្លេបិទទៅទេ?

សាម៉េត: អត់ ។

ដានី: ខ្ញុំអ្នកស្រុកកំណើតនៅកំពង់ចាម ។

សាម៉េត: មកលេងត្រឹមកំពង់ចាម ហើយឃើញសាឡាងទៅតែអត់ដែលបានឆ្លងទៅ ទើបតែខ្ញុំទៅរៀននៅភ្នំពេញ ២០០៨បានឯកឧត្តម ស៊ឹម សារៈ គាត់នាំទៅទស្សនកិច្ចប្រាសាទវត្តនគរបានឆ្លងកាត់ហ្នឹង ។

ដានី: អ៊ំ! ប្រាសាទវត្តនគរទៅខាងឡាវ?

សាម៉េត: បាទ!

ដានី: ជិះកាត់តាមហ្នឹងទៅ?

សាម៉េត: បាទ! ជិះកាត់តាមហ្នឹង ។

ដានី: ខ្ញុំស្រុកកំណើតនៅខាងព្រែកសង្កែ ស្រុកស្ទឹងត្រង់ ចុះពីភ្នំបឹងកេតទៅដល់ ខាងពាមកោះស្នា ។

សាម៉េត: ភ្លេចបាត់អស់ លឺសូរតែឈ្មោះ ។

ដានី: ពេលដែលអ៊ំធ្វើទៅចំការកៅស៊ូ កាលហ្នឹងយើងផលិតកៅស៊ូយ៉ាងម៉េច? ហើយកៅស៊ូយើងនាំចេញយ៉ាងម៉េចដែលកាលហ្នឹង?

សាម៉េត: តាមជំនាន់នោះរៀបចំក្នុងម្នាក់ត្រូវទទួលគេហៅថា១២០០ដើម ។

ដានី: ម្នាក់១២០០ដើម?

សាម៉េត: តែចាំខ្ញុំជំរាប ហ្នឹងដល់លីសូរទៅដូចភ័យបន្តិច ហាក់ដូចជាធ្វើមិនកើត តែ១២០០ដើមគឺថាក្នុង១ថ្ងៃគេដារ៤០០ដើម ដារទី១រួចហើយបានចូលទៅដល់ទី២ ៤០០ដើមទៀត ទី២រួចបានទៅដល់ទី៣ ហើយបានវិលមកដើមវិញ ។

ដានី: យើងចាក់៣ថ្ងៃម្តង?

សាម៉េត: បាទ! ៣ថ្ងៃម្តង ។

ដានី: ៤០០ដើមជិត១ហិចតាហើយអ៊ំ?

សាម៉េត: ដូចជាមិនដល់១ហិចតាព្រោះគេដាំខ្នាតរបស់វាតាមខ្ញុំចាំពេលនោះ យើងយកខ្នាតក្បួនពីបារាំងមក ទ្រូងវា៦ម៉ែត្រ កាំវា៣ម៉ែត្រ ដូនកាលគេសារ៉េទ្រូងវាដល់៧ គេដាំតែ២កន្ទះទេ អា២កន្ទះហើយនិង៧ហ្នឹង វាឲ្យយើងប្រើដីតិចហើយបានដើមច្រើន ហើយដីកាលជំនាន់នោះដីល្អណាស់ ។

ដានី: ដីហ្នឹងដីក្រហម?

សាម៉េត: បាទ! ដាក់អីក៏កើតដែរ ។

ដានី: ដល់ហើយកៅស៊ូយើងបានហើយ យើងយកទៅណាទៅ?

សាម៉េត: មានរោងចក្រនៅកន្លែង ។

ដានី: មានរោងចក្រនៅកន្លែងហ្នឹង?

សាម៉េត: នៅចំការអណ្តូង គេហៅសហជីពលេខ២ សំរាប់មានរោងចក្រធ្វើកៅស៊ូក្រែបតែម្តងចេញជាក្រែបហើយគ្រីបជាគោនៗសំរាប់នាំទៅក្រៅ ។

ដានី: កន្លែសហជីពហ្នឹងនៅចំការលើ ឬនៅណា? នៅថ្នល់បែក ឬនៅណា?

សាម៉េត: បើគិតទៅចាប់ពី យូរទៅពិបាកចាំណាស់ ។ គេហៅថាមុំខាងលិចយើងថ្នល់បែក ។

ដានី: កន្លែងថ្នល់បែកហ្នឹងកន្លែងទីរួមស្រុកចំការលើ ។

សាម៉េត: បាទ! មានខាងត្បូងហ្នឹងក៏មាន ខាងជើងហ្នឹងក៏មាន ខាងលិចមកចំការអណ្តូងក៏មាន ។

ដានី: អ៊ីចឹងកៅស៊ូមានច្រើនកន្លែង តែកន្លែងមន្ទីរអ៊ំស្នាក់នៅ?

សាម៉េត: ខ្ញុំនៅជាប់ចំការអណ្តូង ភូមិចំការអណ្តូង ។

ដានី: ភូមិចំការអណ្តូងនោះវិញ?

សាម៉េត: ហ្នឹងមួយសហជីពមួយភូមិហ្នឹង ។

ដានី: ដូចថាថ្នាក់ដឹកនាំនៅហ្នឹង?

សាម៉េតៈ បាទ! តែមិនមែនតែម្នាក់ទេ វាច្រើនគ្នា ។ ឧទាហរណ៍១២-១៣មានមួយៗ ។ ដែលរួមហ្នឹងបងជន ។

ដានីៈ តាជន គាត់នៅគ្រប់គ្រងរួមហ្នឹង?

សាម៉េតៈ បាទ!

ដានីៈ គ្រប់គ្រងរួមទាំងអស់មួយចំការអណ្តូងឬក៏មាន?

សាម៉េតៈ នៅក្នុងចំការអណ្តូងទាំងមូលហ្នឹង ។

ដានីៈ ហើយកាលហ្នឹងគ្រាន់កន្លែងតំបន់៤២នៅជិតហ្នឹង? នៅថ្នល់បែកហ្នឹង?

សាម៉េតៈ លឺសូរតែអត់ដែលបានទៅទេ ពីព្រោះបើនិយាយពីប្រវត្តិអ្នកចំការកៅស៊ូ អត់មានពេលដើរ លឺសូរតែ៤២ៗតែមិនដឹងទីតាំងកន្លែងណាឲ្យច្បាស់លាស់ ។

ដានីៈ អ៊ំអត់ស្គាល់តាអឿន?

សាម៉េតៈ លឺសូរឈ្មោះ ។

ដានីៈ អនុគាត់ពីណាគេ?

សាម៉េតៈ រិត តែលែងដឹងទៀតហើយ ។

ដានីៈ អ៊ំទៅនោះស្រួលដែរ សុខសប្បាយទេយើងទៅចំការកៅស៊ូ?

សាម៉េតៈ បើនិយាយនៅកន្លែងហ្នឹងសំរាប់ជីវភាពរបស់កម្មករមិនមានអីលំបាកទេ ពីព្រោះបើគិតជំនាន់នោះទៅ ឯខាងផ្សេងទៀតខ្ញុំអត់ដឹងទេ ដឹងតែនៅកន្លែងខ្ញុំគ្រប់គ្រងក្នុងសហជីពមួយរបបស្បៀកពាក់ក្នុងមួយឆ្នាំខោអាវ២កំប្លេ ក្រមាមួយ មុងមួយ ភួយមួយ ប៉ុណ្ណឹងឯង ។ ឯការហូបចុកធម្មតា សំរាប់បើប្រើយើងភាសារឥឡូវហ្នឹងថាល្មមរស់បាន ថ្ងៃបាយល្ងាចបាយ ។

ដានីៈ អ៊ំនៅហ្នឹងរហូតដល់៧៩ ដល់ពេលយួនចូលយ៉ាងម៉េចដែលអ៊ំ? នៅចាំទេព្រឹត្តិការណ៍យួនចូលហើយអ៊ំទៅណាមកណា?

សាម៉េតៈ ខ្ញុំកាលយួនចូលមកបានចាប់ផ្ដើមប្រមូលផ្ដុំគ្នា ទំរាំបានរៀបចំស្រួលរបៀតរបៀយច្រើនយូរដែរ រហូតមកដល់ឆ្នាំ៨១-៨២ ។

ដានីៈ ពេលដែលយួនចូលទៅយើងទៅខាងណា មកខាងណា?

សាម៉េតៈ ផាកមកចំការចេកហ្នឹង ។

ដានីៈ ចំការចេកនៅណា?

សាម៉េតៈ ចំការចេកយើងម្តុំត្រពាំងសង្កែ ។

ដានីៈ ចំការចេក ត្រពាំងសង្កែ ស្រុកអីគេទៅ?

សាម៉េតៈ ហ្នឹងស្រុកចំការលើ ។

ដានីៈ នៅមុំហ្នឹងដែរ? ដល់ពេលយួនចូលយើងនៅហ្នឹងសិន?

សាម៉េតៈ បាទ! នៅហ្នឹងសិន អត់ដឹងទៅណាមកណា ។

ដានីៈ ចុះប្រពន្ធកូន គ្រួសារ-ប្រពន្ធ កូន?

សាម៉េតៈ បែក ចាប់ផ្ដើមបែកគ្នាតាំងពីហ្នឹងមក ។

ដានីៈ អឺបែកប្រពន្ធ គ្រួសារមុនតាំងពីឆ្នាំណា?

សាម៉េតៈ ៧៩ ។

ដានីៈ បែកឆ្នាំ៧៩?

សាម៉េតៈ បាទ!

ដានីៈ បែកទៅគាត់ទៅណា?

សាម៉េតៈ គាត់ទៅស្រុកកំណើតវិញ តែស្លាប់ហើយ អត់ដឹងទំនាក់ទំនង ។

ដានីៈ ដល់ពេលហើយបែកគ្រួសារអឺ ហើយគាត់ត្រឡប់ទៅស្រុក?

សាម៉េតៈ បាទ!

ដានីៈ ចុះកូនចៅ?

សាម៉េតៈ កូនចៅទៅជាមួយគាត់ទាំងអស់ ។

ដានីៈ គាត់ទៅស្រុកកំណើត ស្រុកកំណើតគាត់នៅណាទៅ?

សាម៉េតៈ នៅជាមួយខ្ញុំ

ដានីៈ នៅភូមិ-ឃុំជាមួយគ្នា?

សាម៉េតៈ បាទ!

ដានីៈ បែកគ្នាតាំងពីហ្នឹងមកអីចឹង?

សាម៉េតៈ បាទ!

ដានីៈ អឺកាលអឺនៅកំពង់ចាម នៅចំការអណ្ដូងខស្សាហ៍បានទៅលេងស្រុកទេ ពេលយើងផ្លាស់មក?

សាម៉េតៈ អត់ទេ អីចឹងបានខ្ញុំប្រើពាក្យថាគេដូរ តាមដំណាក់កាលមួយ ភូមិ-ឃុំ ពីមុនក្នុងភូមិនេះឃុំនេះ គេដូរនេះនោះអស់ លំបាកចំណាំ ។

ដានីៈ អឺអាចរៀបរាប់បន្តិចកន្លែងហ្នឹងដូចខ្ញុំចាប់អារម្មណ៍ដែរ ទាក់ទងយួនចូលមកអឺរត់ចូលព្រៃចំការចេក ត្រពាំងសង្កែ ហើយគ្រួសារ ប្រពន្ធកូនបែកគ្នាទៅស្រុក ។

សាម៉េតៈ ដំនាន់នោះនិយាយឲ្យត្រង់វត់យករូបខ្លួន អីចឹងអត់ចាប់អារម្មណ៍ប្រពន្ធកូនៗ ប្រពន្ធកូនគិតដោយប្រពន្ធកូន ខ្លួនយើងគិតទៅតែខ្លួនយើង ព្រោះវាប្រទូសប្រទ្រាស ប្រើពាក្យប្រទូសប្រទ្រាស ។

ដានីៈ ប្រពន្ធកូន គាត់នៅក្នុងស្រុក ក្នុងភូមិ ហើយគាត់ទៅផ្ទះ ឬយួនចាប់បានហើយបញ្ជូនទៅ?

សាម៉េតៈ ទៅផ្ទះតែម្តង ។

ដានីៈ គាត់ទៅផ្ទះតែម្តង?

សាម៉េតៈ បាទ!

ដានីៈ គាត់ទៅជាមួយពីណា?

សាម៉េតៈ គាត់ទៅជាមួយបងប្អូនមកជាមួយគ្នា ។

ដានីៈ កាលហ្នឹងអ្នកដឹកនាំនៅចំការអណ្តូង បែកបាក់ប្រពន្ធកូនច្រើនដែរ?

សាម៉េតៈ បាទ! ច្រើន ។

ដានីៈ ស្ទើរតែទាំងអស់ ឬយ៉ាងម៉េច? បើតាមអ៊ំចាំពីណាខ្លះដែលបែកបាក់ប្រពន្ធ កូនដូចអ៊ំដែរ?

សាម៉េតៈ គាត់ស្លាប់អស់បាត់ហើយតាមចាំ ។

ដានីៈ ពីណាខ្លះ?

សាម៉េតៈ តារ៉េត នោះមួយ ។

ដានីៈ តារ៉េត!

សាម៉េតៈ តែស្លាប់អស់ហើយ មុំ, បឿន ស្លាប់អស់ហើយ ។

ដានីៈ តារ៉េត ។

សាម៉េតៈ រ៉េត ក្មេងនេះមិនមែនទេ ចាស់ហើយ មួយស្រុកខ្ញុំតែស្លាប់អស់ហើយ ។

ដានីៈ ដល់ពេលអីចឹងគាត់មកស្រុកកំណើត អ៊ំនៅខាងចំការចេក ត្រពាំងសង្កែ យើងយ៉ាងម៉េចយើងរៀបចំជាកង់ទ័ពដើម្បីវ៉ៃជាមួយយួនវិញ ឬយ៉ាងម៉េចពេលហ្នឹង?

សាម៉េតៈ កាលហ្នឹងមិនទាន់រៀបចំជាកង់ទ័ពអីទេ ពីព្រោះរស់នៅរងចាំមើលខាងលើ តើរៀបចំយ៉ាងណាៗ ពេលនេះក៏រត់គេចទៅ ពេលដែលអត់អីក៏នាំគ្នាអត់មានបាយ មានតែចេក មានតែខ្នុរ មានតែដំឡូង ។

ដានីៈ មានតែចេក មានតែខ្នុរ ដំឡូង?

សាម៉េតៈ បាទ!

ដានី៖ ហើយយ៉ាងម៉េចទៀតទៅ នៅហ្នឹងបានរយៈពេលប៉ុន្មានបានចេញទៅណាទៀត?

សាម៉េត៖ កាលហ្នឹងតាមខ្ញុំចាំ ៨២-៨៣គេប្រមូលឡើងមកលើភ្នំ ។

ដានី៖ អីចឹងកាលពី៧៩-៨០នៅម្តុំចំការចេក ត្រពាំងសង្កែហ្នឹងទេ?

សាម៉េត៖ បាទ ។

ដានី៖ កាលហ្នឹងពីណាគេអ្នកដឹកនាំ?

សាម៉េត៖ អត់ទាន់មានច្បាស់ទេ នៅជាក្រុមៗ ។

ដានី៖ អត់មានក្រុមធំ?

សាម៉េត៖ ក្រុមតូចៗ ១០នាក់-១៥នាក់ ។

ដានី៖ ដល់ពេលចេញពីចំការចេក ត្រពាំងសង្កែមកណាទៅ?

សាម៉េត៖ ឡើងមកលើភ្នំ ។

ដានី៖ ចេញតាមណា?

សាម៉េត៖ ចេញមកពីចំការលើមកដើង ធ្លាក់យើងម្តុំដែប ថន្លាបរិវ៉ាត់ បានឡើងបុកមកច្រក ១០០១ ។

ដានី៖ ចេញមក យើងចេញមកច្រក១០០១?

សាម៉េត៖ បាទ!

ដានី៖ ហើយមកច្រើនទេ កំលាំងមក?

សាម៉េត៖ ប្រមូលម្តុំហ្នឹងច្រើនដែរ ជាប់រាប់ពាន់នាក់ ។

ដានី៖ សុទ្ធតែក្រុមសហជីព?

សាម៉េត៖ អត់ទេ និយាយតាំងពីកងទ័ព តាំងពីប្រជាពលរដ្ឋ សហជីពបូកចូលគ្នារាប់ពាន់នាក់តាម មើល ។

ដានី៖ ទាំងសហជីពបូកបញ្ចូលគ្នារាប់ពាន់នាក់ដែរ?

សាម៉េត៖ បាទ!

ដានី៖ ឆ្នាំប៉ុន្មានទៅឡើងមកដល់កន្លែង១០០១?

សាម៉េត៖ អត់ច្បាស់ប្រហែលជា៨២ ហ្នឹងប្រហែលទេ តែក្នុងរង្វង់ពីរអស់ហ្នឹង បើមិន៨១-៨២, ៨៣-៨២ ក្នុងហ្នឹង ។

ដានី៖ ពេលឡើងមកដល់១០០១យ៉ាងម៉េចទៀតទៅ?

សាម៉េត៖ ដល់១០០១ហ្នឹងមានរៀបចំជាកងហើយ ។

ដានី៖ មកដល់១០០១រៀបចំជាកងយ៉ាងម៉េចវិញទៅ?

សាម៉េតៈ	រៀបចំជាកងទ័ពតែម្តង ។

ដានីៈ	មានកងពលនៅ?

សាម៉េតៈ	ចូលជាកងពលហើយ ។

ដានីៈ	អ៊ំនៅកងពលណាទៅ?

សាម៉េតៈ	ខ្ញុំនៅកងពល៤១៧ ។

ដានីៈ	មកនៅក្នុងកងពល៤១៧?

សាម៉េតៈ	បាទ! ព្រោះកងពល៤១៧និយាយមែនទែនទៅ វាជាកងពលរបស់ភូមិភាគកណ្តាល ។

ដានីៈ	កងពល៤១៧គេចាប់រៀបចំពីអង្កាល់មក?

សាម៉េតៈ	ឡើងមកជួបគ្នានៅលើភ្នំ ។

ដានីៈ	ឆ្នាំ៨២បានមានកងពល៤១៧ ឬគេមានតាំងពីមុនហ្នឹង?

សាម៉េតៈ	មកច្បាស់នៅ៨២ហ្នឹងតែម្តង ។

ដានីៈ	អ៊ំមកកងពល៤១៧ធ្វើអីវិញទៅ?

សាម៉េតៈ	កាលហ្នឹងរៀបចំឲ្យធ្វើជាវរសេនាតូច ។ កាលហ្នឹងមានកំលាំងប្រហែលជា៣០ នាក់ ។

ដានីៈ	តិចម៉្លេះ? កាលអ៊ំនៅអនុសេនាធំមានដល់មួយរយជាង?

សាម៉េតៈ	ហ្នឹងកាលជំនាន់យើងរៃអាមេរិច ។

ដានីៈ	ដល់ពេលសម័យនេះគ្នាតិចវិញ?

សាម៉េតៈ	គ្នាតិច ពីព្រោះគ្នាតិច វាជាសកម្មភាពឈ្លប ។

ដានីៈ	អ៊ំវរសេនាតូច នៅក្នុងវរសេនាធំណាទៅ?

សាម៉េតៈ	វរសេនាធំ៧១ ។

ដានីៈ	អីចឹង៤១៧ មានវរសេនាធំ៧១,វរសេនាធំចិតប៉ុន្មានទៀត?

សាម៉េតៈ	៧១, ៧២, ៧៣, ៧៤, ៧៥ ។

ដានីៈ	មានច្រើនវរសេនាធំដែរ ។

សាម៉េតៈ	បាទ!

ដានីៈ	មាន៥វរសេនាធំ?

សាម៉េតៈ	បាទ!

ដានីៈ	ប្រធានកងពលពីណាគេ?

សាម៉េតៈ	អ៊ំពក ។

ដានីៈ	បន្ទាប់គាត់?

សាម៉េតៈ ដូចជាបងប៉ូច ។

ដានីៈ អ៊ំប៉ូច?

សាម៉េតៈ បាទ!

ដានីៈ ពីណាទៀតអ៊ំ?

សាម៉េតៈ ដូចជាខ្មោចតាអឿន, ខ្មោចតាលឹម មួយទៀត ។

ដានីៈ ហើយវរៈ៧១ ពីណាប្រធានវរៈ?

សាម៉េតៈ កាលហ្នឹងគេចែកគ្នា ឧទាហរណ៍ក្នុងគណៈកងពលទទួលវរសេនាធំមួយ ។

ដានីៈ អីចឹង៧១ពីណាគេអ្នកទទួល?

សាម៉េតៈ អ៊ំប៉ូច ។

ដានីៈ ហើយ៧២?

សាម៉េតៈ ៧២នេះអ៊ំជុំ ។

ដានីៈ ជុំ ជាតិ ។ ៧៣?

សាម៉េតៈ ខ្មោចតាលឹម ស្លាប់បាត់ ។

ដានីៈ គាត់ស្លាប់នៅណាទៅ?

សាម៉េតៈ ស្លាប់ជំងឺ ។

ដានីៈ ដល់៧៤?

សាម៉េតៈ ៧៤ខ្មោចបងឆាំ ហើយតាអឿន ៧៥ ។ វាដូចវ៉ាក់ដែលយូរ ។

ដានីៈ ហើយកងពលហ្នឹងក្រោយមកមានប្តូរផ្លាស់អីទៀតដែលអត់?

សាម៉េតៈ អត់មានទេ ។

ដានីៈ គណៈកងពលនៅដដែល?

សាម៉េតៈ បាទ! នៅដដែល ។

ដានីៈ ហើយដល់ឆ្នាំ៨២ហ្នឹងអ៊ំឡើងដល់កន្លែង១០០១ យើងបង្កើតជាកងពលហើយយើងនៅដដែល ឬត្រូវចុះមក?

សាម៉េតៈ ចុះមកក្រោម ។

ដានីៈ មកធ្វើប្រតិបត្តិការនៅណាទៅ?

សាម៉េតៈ ខ្ញុំនៅកំពង់ធំ ។

ដានីៈ ចុះមកនៅកំពង់ធំ?

សាម៉េតៈ ស្រុកសណ្តាន់ ។

ដានី៖ តែមួយស្រុកទេ?

សាម៉េត៖ ស្រុក ។

ដានី៖ តែកងពលហ្នឹង?

សាម៉េត៖ ពេលនោះមួយកងពលគេចែកជាពមុខសញ្ញា ។

ដានី៖ មុខសញ្ញាណាខ្លះទៅ?

សាម៉េត៖ មានសន្ទុក មានសណ្ដាន់ មានកំពង់ស្វាយ ។

ដានី៖ តែពហ្នឹងទេ?

សាម៉េត៖ តែព ។

ដានី៖ ខាងកំពង់ចាមអត់មានទេ?

សាម៉េត៖ កំពង់ចាមមានដូចគ្នា ហ្នឹងផ្នែកខាងបងជុំ ។

ដានី៖ អីចឹងកងពលហ្នឹងប្រតិបត្តិការក្នុងខេត្តកំពង់ធំ កំពង់ចាម?

សាម៉េត៖ បាទ!

ដានី៖ មានទៅខេត្តណាទៀតដែលអត់?

សាម៉េត៖ នៅព្រែកប្រសព្វមួយទៀត តែសុទ្ធតែស្លាប់អស់ហើយ ។

ដានី៖ អីចឹងតាជុំ គាត់ខាងកំពង់ចាម?

សាម៉េត៖ បាទ!

ដានី៖ ខាងកំពង់ធំ?

សាម៉េត៖ ប៉ូច ។

ដានី៖ ខាងតាលឹម, តាអឿន ខាងណាវិញ?

សាម៉េត៖ បងលឹម មិនដឹងទៅកងមាស ឬមុខកំពូល អត់ច្បាស់កន្លែងហ្នឹង ។

ដានី៖ តាជុំ គាត់ខាងកំពង់ចាម ខាងស្រុកអីខ្លះ?

សាម៉េត៖ ចំការលើ ។

ដានី៖ បើខាងតាលឹម អាចមុខកំពូល អាចកងមាស?

សាម៉េត៖ បាទ! អាចជាមួយខ្មោចបងឆាំ ពីរហ្នឹងគេចុះទៅគេចាប់ដៃគ្នា តែគេចែកមុខព្រួញគ្នាតែមិនដឹងទៅខាងណា ។

ដានី៖ ដល់ខាងព្រែកប្រសព្វ?

សាម៉េត៖ ព្រែប្រសព្វខ្មោច វឿន តែស្លាប់បាត់ហើយ ។

ដានី៖ ឈ្មោះអីគេ?

សាម៉េតៈ រឿនៗ

ដានីៈ រឿន ហ្នឹងគាត់ជាស្អីគេកាលហ្នឹង?

សាម៉េតៈ កាលហ្នឹងគាត់ប្រធានវរសេនាធំៗ

ដានីៈ ប្រធានវរសេនាធំលេខប៉ុន្មានទៅ?

សាម៉េតៈ ដូចភ្លេចបាត់ហើយៗ

ដានីៈ នៅក្នុង?

សាម៉េតៈ នៅក្នុងព្រែកប្រសព្វហ្នឹងៗ

ដានីៈ នៅក្នុងមានវរសេនាធំ៧១, ៧២, ៧៣, ៧៤, ៧៥ គាត់នៅក្នុងមួយណាទៅ?

សាម៉េតៈ នៅក្នុង៧២ តែគាត់ទៅព្រែកប្រសព្វៗ

ដានីៈ ចំការលើ ស្ទឹងត្រង់ ព្រែកប្រសព្វ អីហ្នឹងៗ អ៊ំចុះទៅខាងណា?

សាម៉េតៈ កំពង់ធំៗ

ដានីៈ កំពង់ធំ ចុះទៅម្ដុំណា? មុខព្រួញណា?

សាម៉េតៈ មុខព្រួញសណ្ដាន់ៗ

ដានីៈ នៅខាងសណ្ដាន់ហ្នឹងបានរយៈពេលប៉ុន្មានទៅ?

សាម៉េតៈ ៣-៤ឆ្នាំដែរៗ ដូចជា២-៣ឆ្នាំមិនដឹងទេ អត់ចាំច្បាស់ៗ

ដានីៈ ចេញពីហ្នឹងមកណាវិញទៀត?

សាម៉េតៈ មកជាន់មីនតែម្ដងៗ

ដានីៈ អ៊ំជាន់មីនឆ្នាំណាទៅ?

សាម៉េតៈ ដូច៨៤-៨៥ មិនដឹង វានៅក្នុងវង្វង់ហ្នឹងអត់បានចាំច្បាស់ៗ

ដានីៈ ដល់ពេលអ៊ំត្រូវរបួសជាន់មីនហើយយ៉ាងម៉េចទៀតទៅ?

សាម៉េតៈ បញ្ជូនមកឡើងភ្នំៗ

ដានីៈ បញ្ជូនមកនៅណាវិញ?

សាម៉េតៈ មកនៅ១០០១ៗ

ដានីៈ អ៊ំពិការហើយយើងឈប់ធ្វើជាកងទ័ពទៅមុខទៀតហើយ?

សាម៉េតៈ បាទ!

ដានីៈ មកនៅកន្លែងណាវិញទៅ?

សាម៉េតៈ មកនៅលើភ្នំ នៅប្រក១០០១ៗ

ដានីៈ មកគ្រប់គ្រងប្រជាជនវិញ?

សាម៉េតៈ បាទ!

ដានីៈ ហ្នឹងឆ្នាំហ្នឹងនៅ១០០១នៅឡើយទេ?

សាម៉េតៈ បាទ!

ដានីៈ ជាមួយពីណាខ្លះទៅដូចថាគ្រប់គ្រងប្រជាជនជាមួយអ៊ំ?

សាម៉េតៈ ស្លាប់អស់ខ្លះហើយ មិននៅជុំគ្នាទេ កាលហ្នឹងដល់ពេលនិយាយទៅមុខតិចចុះ មកកិច្ចព្រមព្រៀងហើយដល់យើងចុះមកក៏បែកគ្នា ខ្លះទៅក្នុង ខ្លះនៅនេះ ទៅនៅចំការលើមួយចំនួនទៅ នៅនេះមួយចំនួន ដល់អ៊ីចឹងបែកគ្នាខ្ចាត់ខ្ចាយអស់ទៅ គេទៅក្នុងគេសុខទុក្ខទៅសុខទុក្ខធម្មតា យើងនៅនេះក៏រៀងមួយផ្សេងទៀតទៅ ។

ដានីៈ ពេលហ្នឹងពេលដែលអ៊ំទៅដល់កន្លែង១០០១ ដូចថានៅបានយូរទេបានយួនវៃបែកយើងវត់ ដូចថាបែកនៅ១០០១ហ្នឹង?

សាម៉េតៈ តាមមើលខ្ញុំឡើងទៅក្រោយវៃ១០០១ តាមមើលអ៊ី ដល់ខាងលើបែកហើយបានខ្ញុំទៅតាមក្រោយ ។

ដានីៈ បែកហើយអ៊ីចឹង?

សាម៉េតៈ បាទ!

ដានីៈ អ៊ីចឹងអ៊ំឡើងទៅ១០០១នៅកន្លែងណាវិញ? កន្លែងមុំ៣គេវៃបែកហើយអ៊ីចឹង?

សាម៉េតៈ ហ្នឹងហើយ មកនៅដូចជាច្រកម្តុំ ខ្ញុំមិនសូវចាំដែរដីថៃ ។

ដានីៈ អត់សូវចាំ?

សាម៉េតៈ អត់សូវចាំទេ ។ គាត់ស្គាល់អូរត្រាវពីមុន?

ដានីៈ លឺៗឈ្មោះអូរត្រាវ ។

សាម៉េតៈ នៅខាងកើតអូរត្រាវ ។

ដានីៈ តែយើងពីមុនយើងទៅច្រក១០០១ ពេលយួនវៃបែកយើងមកខាងហ្នឹង យើងនៅម្តុំគ្នាយើងដដែល?

សាម៉េតៈ បាទ!

ដានីៈ ១០០១បើតាមអ៊ំចាំគេវៃបែកឆ្នាំណា? យួនវៃបែក?

សាម៉េតៈ ដូចជា៨៥-៨៦ ខ្ញុំអត់ច្បាស់ តែក្នុងរង្វង់អស់ហ្នឹង ជំនាន់កេណ្ឌប្រជាពលរដ្ឋមកក-៥

ដានីៈ ជំនាន់ហ្នឹងឆ្នាំ៨៥ ។

សាម៉េតៈ បាទ!

ដានី: ហើយពេលហ្នឹង ពេលដែលយើងបែកពី១០០១ កាលហ្នឹង១០០១មកនៅក្នុងដីអីវិញ ហើយ? មកនៅក្នុងដី១០០២, ១០០៣?

សាម៉េត: អត់ទេ បែកដោយឡែក មកនៅខាងកើតនៅ១០០១ដដែល ខាងលិច១០០៣ដដែល ១០០២មកខាងលិចទៀត ហ្នឹងខ្ញុំអត់ដែលមកទេ តែលឺសួរថា១០០២នៅខាងលិច ១០០៣ ។

ដានី: ១០០២នៅកន្លែងគេហៅម៉ុំអី?

សាម៉េត: អត់ច្បាស់ អត់ដែលមកផង នៅជួរភ្នំហ្នឹងតែមិនដឹងនៅកន្លែងណា ។ តាមខ្ញុំចាំ១០០១ ជំរំអូរត្រាវ ។

ដានី: អីចឹងពួក១០០៣អត់មានមកនៅជំរំអូរត្រាវជាមួយទេ?

សាម៉េត: អត់ទេ នៅខាងលិចអូរត្រាវ ។

ដានី: គេហៅអីគេវិញ១០០៣? ពួកគាត់នៅខាងអីវិញ?

សាម៉េត: ដូចជារកឆ្លើយមិនឃើញ ព្រោះអត់ចាំឈ្មោះព្រោះដើរទៅដើរមកជាប់ជាមួយគ្នា តែឈ្មោះដីថៃអត់បានចាំ ។

ដានី: អ៊ំរៀបគ្រួសារថ្មីឆ្នាំណាវិញទៅ? ដូចថាអ៊ំបែកគ្រួសារ អ៊ំទៅខាងស្រុកកំណើត ។

សាម៉េត: ខ្ញុំដូចជា៨៤ ។

ដានី: នៅចន្លោះហ្នឹងអ៊ំមានដែលស៊ើបសួររកគ្រួសារ?

សាម៉េត: សួរ តែអត់ឃើញ ដល់សន្តិភាពហើយបានដឹងថាគាត់ទៅនៅស្រុក ។

ដានី: ដែលបានជួបគ្នាវិញទេ?

សាម៉េត: ជួបម្តងដែរ តែគាត់ឈឺ និយាយស្មាទោស មិនដឹងគាត់ស្លាប់ឬរស់ ព្រោះគាត់កើតទាច

ដានី: ឆ្នាំណាបានជួបគាត់វិញ?

សាម៉េត: យើងផ្សះផ្សារជាតិហើយ ។

ដានី: ផ្សះផ្សារឆ្នាំ៩៨?

សាម៉េត: បាទ! ៩៨ ។

ដានី: ដល់ហើយអ៊ំទៅស្រុក?

សាម៉េត: បាទ!

ដានី: ទៅបានជួបគាត់?

សាម៉េត: ទៅបានជួប ។

ដានី: ជួបយ៉ាងម៉េចទៅអារម្មណ៍ ឬម៉េចពេលហ្នឹង?

សាម៉េតៈ គាត់ថាទៅអីចឹងហើយ ពាក្យចាស់ៗថាតាមដំណើរកុំឲ្យមានកម្មពៀរគ្នាទៀត ។

ដានីៈ គាត់អត់មានគ្រួសារថ្មីទេ?

សាម៉េតៈ អត់ទេ ។

ដានីៈ ឆ្នាំ៨៤អ៊ំរៀបគ្រួសារថ្មី គ្រួសារអ៊ំក្រោយអ្នកនៅខាង?

សាម៉េតៈ អ្នកកំពង់ធំ ។

ដានីៈ ចុះកូនចៅអ៊ំមុនៗគាត់មានមកនៅខាងនេះ?

សាម៉េតៈ អត់ទេ មកលេងមក តែអត់នៅ ។

ដានីៈ អ៊ំរៀបគ្រួសារឆ្នាំ៨៤ មុន?

សាម៉េតៈ មុនពិការជើង ។

ដានីៈ រៀបការបានរយៈពេលប៉ុន្មានបានពិការ?

សាម៉េតៈ ប្រហែលជាជាប់១ឆ្នាំជាង ។

ដានីៈ ដល់អ៊ំពិការត្រឡប់មកនៅជាមួយគ្រួសារវិញ ឬយ៉ាងម៉េច?

សាម៉េតៈ គេបញ្ជូនឲ្យទៅលើ ទាំងគ្រួសារទៅភ្នំដងរែក ។

ដានីៈ មកកន្លែងណាវិញទៅ?

សាម៉េតៈ មកប្រក១០០១ អាហ្នឹងវាចេះ កន្លែងដែលវៃខ្វាត់ខ្វាយវានៅតែប្រក១០០១ គ្រាន់តែគេដូរកន្លែង ។

ដានីៈ បានន័យថាគេវៃបែកនៅមុំ៣ តែដូរមកទៀតគេនៅតែហៅថាប្រក១០០១?

សាម៉េតៈ នៅតែហៅ ។

ដានីៈ តែប្រក១០០១ក្រោយនេះនៅ គេហៅកន្លែងណា?

សាម៉េតៈ ខាងកើតអូរត្រាវ ។

ដានីៈ ឈ្មោះអីទៅ?

សាម៉េតៈ ខ្ញុំវាអត់ចាំ ស៊ីងចាន់ ។

ដានីៈ ស៊ីងចាន់ហ្នឹងប្រក១០០១?

សាម៉េតៈ បាទ!

ដានីៈ ដល់ពេលប្រក១០០២ គេហៅកន្លែងអី? ប្រក១០០១កាលពីដំបូងមុំ៣ ទន្លេល្ពៅ ដល់ពេលគេវៃបែកឆ្នាំ៨៥មកស៊ីងចាន់ ដល់១០០៣គេហៅអីវិញ? ១០០២ប្រកអី?

សាម៉េតៈ ចាំតែដំរំអូរត្រាវ ខាងលិចដំរំអូរត្រាវគេហៅស្អឺអត់បានសួរ ។

ដានី៖ ១០០៧ អត់ដឹង។ ១០០៣ អត់ដឹងដែរ។

សាម៉េត៖ ដឹងតែចំណុចគេនៅខាងលិច ១០០៣នៅខាងលិចអូរគ្រាវហ្នឹង។

ដានី៖ ចុះ១០០៧?

សាម៉េត៖ ហ្នឹងរឹតតែលែងដឹងទៀត។

ដានី៖ ១០០៣នៅខាងលិចអូរគ្រាវ។ ដល់១០០៧នៅខាងណាអូរគ្រាវវិញ?

សាម៉េត៖ ខាងលិច១០០៣ទៀត តែមិនដឹងចំណុចនៅត្រង់ណា។

ដានី៖ ដល់ពេលអ៊ីចឹង ពេលអ៊ំមកឡើងភ្នំនៅក្រោយ អ៊ំគ្រប់គ្រងប្រជាជន?

សាម៉េត៖ បាទ!

ដានី៖ គ្រប់គ្រងប្រជាជនទាំងមូលនៅប្រក១០០១ឬអត់ទេ?

សាម៉េត៖ នៅក្នុងក្របខណ្ឌវរសេនាធំ៧១។

ដានី៖ ចុះអ៊ំប៉ូច គាត់ពិការគាត់មកគ្រប់គ្រងប្រជាជនដែរ?

សាម៉េត៖ ខ្ញុំពិការបាន១ឆ្នាំ គាត់ពិការក្រោយខ្ញុំ គាត់ឡើងមក ហ្នឹងគាត់ទទួលរួមជាមួយខ្មោចអ៊ំពក

ដានី៖ ជាមួយអ៊ំកែ ពក?

សាម៉េត៖ បាទ!

ដានី៖ ដល់ពេលហ្នឹងគេរៀបចំគណៈកងពលថ្មី?

សាម៉េត៖ ហ្នឹងកងពលថ្មីគេរៀបចំ។

ដានី៖ កងពលថ្មីពីណាវិញទៅ?

សាម៉េត៖ មានខ្មោចតាពេជ ជាង។

ដានី៖ ពីណាទៀត?

សាម៉េត៖ ជាមួយខ្មោចតាឆាំ ជាមួយតាជុំ ខ្មោចលីន។

ដានី៖ លឹម ឬលីន?

សាម៉េត៖ លីន។

ដានី៖ តាលីន គាត់ស្លាប់យូរហើយ ឬទើបនឹងស្លាប់?

សាម៉េត៖ ស្លាប់យូរគួរសម។ បានជាខ្ញុំអត់សូវច្បាស់ ពីព្រោះគេចែកគ្នាដាច់ អ្នកដែលនៅខាងលើ គេនៅខាងលើ អ្នកក្រោមគេមានផ្នែកតាមអង្គភាពអ្នក។

ដានី៖ អ្នកខាងក្រោមគេមានអង្គភាពរបស់គេ?

សាម៉េត៖ បាទ!

ដានី៖ អង្គភា៣២ហ្នឹងតែនៅក្នុងកងពលតែមួយ?

សាម៉េតៈ តែមួយ ។

ដានីៈ មួយប្រជាជន មួយកងទ័ព?

សាម៉េតៈ បាទ!

ដានីៈ អីចឹងអ៊ំនៅកន្លែងស្ទឹងចាន់ អូរត្រាវ រយៈពេលប៉ុន្មានទៅបានផ្លាស់ប្តូរកន្លែងទៀត?

សាម៉េតៈ ទាល់តែ១៩៩៣យើងមានកិច្ចព្រមព្រៀង ។

ដានីៈ យើងមានកិច្ចព្រមព្រៀងទីក្រុងបារីសហ្នឹង?

សាម៉េតៈ បាទ!

ដានីៈ កិច្ចព្រមព្រៀងទីក្រុងបារីស១៩៩១ បានចាប់ផ្តើម បន្ទាប់មកមានអ៊ុនតាក់ចូលមក ដល់ឆ្នាំ៩៣បានយើងបោះឆ្នោត ។

សាម៉េតៈ ៩១ហ្នឹងគឺយើងបានចល័តកន្លែងចុះមកក្នុងដីខ្មែរ ដោយយោងតាមកិច្ចព្រមព្រៀង ១៩៩១ ហើយបោះឆ្នោត១៩៩៣ ។

ដានីៈ ដល់អីចឹងឆ្នាំ៩១ចុះមកនៅខាងនេះ?

សាម៉េតៈ ចុះមកនៅក្នុងដីខ្មែរ ។

ដានីៈ អ៊ំអាចរៀបរាប់កន្លែងហ្នឹងតិច តើពេលដែលឆ្នាំ៩១យើងចុះមកដំបូង យើងនៅកន្លែងណាខ្លះទៅ ពី១០០១យើងនៅពីត្រឹមណាដល់ត្រឹមណា?

សាម៉េតៈ ពី១០០១ ចុះមកម្តុំភូមិបងប៉ូចបង្កើត ។

ដានីៈ ភូមិគាត់នៅខាងថ្លាត?

សាម៉េតៈ បាទ!

ដានីៈ ពីថ្លាតមកដល់?

សាម៉េតៈ មកកើត ។

ដានីៈ ចាប់ពីថ្លាតភូមិរបស់អ៊ំប៉ូច មកដល់ខាងកើតគេហៅអីទៅ? កន្លែងណា?

សាម៉េតៈ មកដល់ទំនប់ដាច់យើងនេះ ។

ដានីៈ ហ្នឹងក្រុម១០០១?

សាម៉េតៈ បាទ!

ដានីៈ និយាយទៅ១០០១, ១០០២, ១០០៣ កំលាំងខាងណាច្រើនជាង?

សាម៉េតៈ ដូចជាពិបាកប៉ាន់ស្មាន ។

ដានី:	ដល់អីចឹងយើងចុះមកហូរហែរពីកន្លែងអីប៉ូច រហូតដល់ទំនប់ដាច់ ចាប់ពីថ្នាត។ ចុះមកយើងរស់នៅជារបៀបយ៉ាងម៉េច? យើងចុះមកតាមកងៗ ឬតាមកងពលចាត់តាំងអ្នកនេះម្ដុំនេះ ឬយ៉ាងម៉េច?

សាម៉េត:	តាមរៀបចំកន្លែងតាមកងពលមួយៗ កងពលមួយៗរៀបចំតាមវរសេនាធំ វរសេនាធំរៀបចំតាមវរសេនាតូច។ ឧទាហរណ៍កងពល៤១៧រៀបចំនៅម្ដុំ វរសេនាធំទាំងអស់សុទ្ធតែមានកំលាំងនៅក្រោយ ដែលកំលាំងមកមុខតែមានកំលាំងនៅខាងក្រោយ អីចឹងគេរៀបចំវរសេនាតូចមួយជាភូមិ វរសេនាតូចមួយជា១ភូមិៗ។

ដានី:	វរសេនាតូចមួយនៅមួយភូមិៗ ដល់ពេលវរសេនាធំ?

សាម៉េត:	នៅក្នុងចំណោមវរសេនាធំ វាមាន៣វរសេនាតូច តែរៀបចំភូមិ ឯវរសេនាធំផ្សេងទៀត រៀបចំភូមិដូចគ្នាហើយមានរៀបចំអ្នកទទួលខុសត្រូវរួម២-៣នាក់ ជំនួសមុខកងពល មានបងប៉ូច។

ដានី:	ត្រពាំងប្រាសាទដំបូងពីណាគេឲ្យរៀបចំឲ្យពីណាគេគ្រប់គ្រងរួម នៅត្រពាំងប្រាសាទ? ដែលយើងចុះមកដំបូង?

សាម៉េត:	ហ្នឹងវាច្រើនគន្ទាក់បន្តិច ពេលមានកិច្ចព្រមព្រៀង៩១ហើយ វាអត់មានស៊ី ចង់និយាយថាខាងនេះទទួល អាហ្នឹងខ្ញុំមិនយល់ច្បាស់ទេ អត់មានការយល់ស្របនឹងកិច្ចព្រមព្រៀងបានរៀបចំជាស្រុក ស្រុកមួយអន្លង់វែង ស្រុកមួយទៀតត្រពាំងប្រាសាទ។

ដានី:	ពីឆ្នាំណាហ្នឹង?

សាម៉េត:	១៩៩១។

ដានី:	អីចឹងខាងខ្មែរក្រហមយើងរៀបចំបែងចែករៀបចំខ្លួនឯងរួចស្រេចហើយ?

សាម៉េត:	បាទ!

ដានី:	ពី១៩៩១ព្រមព្រៀងគ្នាថាមួយត្រពាំងប្រាសាទ មួយអន្លង់វែង?

សាម៉េត:	បាទ!

ដានី:	យ៉ាងម៉េចទៀតទៅ?

សាម៉េត:	ហើយបានរៀបចំខាងត្រពាំងប្រាសាទចាប់ពីត្រង់ហ្នឹងទៅ មូលដ្ឋានហ្នឹងមកទៅទំនប់ដាច់ទៅកើត ហើយអន្លង់វែងចាប់ពីផ្លូវទៅលិច។

ដានី:	ដល់ពេលគេរៀបចំអីចឹងហើយ គេរៀបចំចាត់តាំងអ្នកណាគ្រប់គ្រងស្រុក។ កាលហ្នឹងពីណាខ្លះទៅពីដំបូងហ្នឹង?

សាម៉េត:	តាមខ្ញុំចាំដំបូងនៅស្រុកហ្នឹងមានបងម្នាក់មកឈ្មោះ ចាន់ ស៊ីន់ ស្គាល់ទេ?

ដានី៖ បាទ! គាត់គ្រប់គ្រងរួម គាត់ជំរាបប្រាប់ខ្ញុំដែរ ។ ជាមួយពីណា?

សាម៉េតៈ ហើយកាលហ្នឹងមានបងម្នាក់នៅអូរស្វាយ មានខ្ញុំ ។

ដានី៖ ពីណាគេនៅអូរស្វាយ?

សាម៉េតៈ បងស៊ី ។

ដានី៖ ប៊ុន ស៊ី?

សាម៉េតៈ បែប ប៊ុន ស៊ី ហ្នឹងហើយតាមមើលខ្ញុំស្គាល់តែឈ្មោះ ស៊ីៗ ។ គាត់កើតរោគលើសឈាម ។

ដានី៖ អ៊ំស្គាល់គាត់យូរនៅ?

សាម៉េតៈ ស្គាល់គាត់មកនៅនេះដែរទេ ។

ដានី៖ មកនៅណា?

សាម៉េតៈ មកនៅយើងនេះ ក្រោម ។

ដានី៖ កាលមុនគាត់នៅណា?

សាម៉េតៈ គាត់នៅតាកែវ តែមិនដឹងគាត់នៅត្រង់ណា ។

ដានី៖ អ៊ំស៊ន់ ស្គាល់គាត់យូរដែរ?

សាម៉េតៈ ស្គាល់គ្នាមកនៅនេះ គាត់នៅកំពត ។

ដានី៖ ចាំមើលកាលជំបូងអ៊ំស៊ន់, អ៊ំស៊ី ហើយអ៊ំ ពីណាទៀតដែលចាត់តាំងឲ្យគ្រប់គ្រងស្រុក?

សាម៉េតៈ ខាងនារីយាយស៊ុន តាញ៉ន ។

ដានី៖ យាយស៊ុន?

សាម៉េតៈ យាយស៊ុន, យាយមឿន ។

ដានី៖ យាយមឿនប្រពន្ធតាពក មិនមែនទេ?

សាម៉េតៈ មិនមែនទេ ។

ដានី៖ យាយស៊ីន ប្ដីគាត់ឈ្មោះ?

សាម៉េតៈ តាញ៉ន ។

ដានី៖ យាយស៊ីន-តាញ៉ន ។ តាញ៉ន កងពលហ្នឹង?

សាម៉េតៈ បាទ!

ដានី៖ សព្វថ្ងៃក្រែងតាញ៉ន នៅសៀមរាប?

សាម៉េតៈ នៅសៀមរាប ។

ដានី៖ យាយស៊ីន ឥឡូវគាត់ទៅនៅសៀមរាបដែរ?

សាម៉េតៈ បាទ! សៀមរាប ។

ដានីៈ ចុះយាយមឿន?

សាម៉េតៈ ខ្ញុំអត់ច្បាស់ដែរដល់យើងបែកគ្នាយូរដែលហើយ ជិត១៥ឆ្នាំ ។

ដានីៈ យាយមឿន គាត់នៅនេះ?

សាម៉េតៈ មិនដឹងជានៅនេះ ឬទៅនៅឯណា ព្រោះដល់នេះគេអាចចល័តរកបងប្អូន ។

ដានីៈ ដល់គេបែងចែកចាប់ផ្តើមរៀបចំនៅខាងត្រពាំងប្រាសាទអីមានប្រសាសន៍មិញ ចុះនៅខាងអន្លង់វែងពីណាគេខ្លះ?

សាម៉េតៈ ខាងអន្លង់វែងអត់ច្បាស់ទេ ។

ដានីៈ ដឹងច្បាស់តែនៅត្រពាំងប្រាសាទ ។ កាលហ្នឹងបែងចែកជាស្រុកត្រពាំងប្រាសាទ កាលហ្នឹងមានប៉ុន្មានឃុំដំបូងពី៩១មក?

សាម៉េតៈ ពី៩១មក ដូច៦ឃុំដូចសព្វថ្ងៃ ។ មានព្រះប្រឡាយ, មានផ្អាវ, មានឃុំអូរស្វាយ, ទំនប់ដាច់, បាក់អន្លង់នេះដាក់ឈ្មោះថ្មីទេ ពីមុនឃុំត្រពាំង៣ តែឥឡូវដាក់ឈ្មោះថ្មីបាក់អន្លង់ ហើយត្រពាំងប្រាសាទ ។

ដានីៈ អតីតឃុំត្រពាំង៣ទេ?

សាម៉េតៈ បាទ!

ដានីៈ ព្រះប្រឡាយ, បាក់អន្លង់, អូរស្វាយ, ត្រពាំងប្រាសាទ ។

សាម៉េតៈ ផ្អាវ ។

ដានីៈ ពី៩១មកអីចឹងដែរ?

សាម៉េតៈ បាទ! អីចឹង ។

ដានីៈ កាលហ្នឹងពីណាទទួលនៅព្រះប្រឡាយ?

សាម៉េតៈ ដូរគ្រឡប់គ្រឡិនអស់ហើយ ។

ដានីៈ កាលដំបូង ។

សាម៉េតៈ ចាន់ ពឿន ។

ដានីៈ គាត់ទៅណាឥឡូវ?

សាម៉េតៈ នៅធ្វើជំទប់ទី២ ។

ដានីៈ ធ្វើជំទប់ទី២នៅព្រះប្រឡាយហ្នឹង?

សាម៉េតៈ បាទ!

ដានីៈ ចុះទំនប់ដាច់?

សាម៉េត:	បងម្នាក់អគ្គុយនេះ សយ ។

ដានី:	សារី សយ ។

សាម៉េត:	បាទ!

ដានី:	គាត់ទទួលជំបូង?

សាម៉េត:	បាទ!

ដានី:	ចុះត្រពាំងពា បាក់អន្ទង?

សាម៉េត:	កាលហ្នឹងខ្ញុំហើយពីរនាក់បងម្នាក់ ។

ដានី:	អ៊ំទទួលស្រុកហើយទទួលឃុំមួយដែរ?

សាម៉េត:	កាលជំនាន់ហ្នឹងមកស្រុកផង ឃុំផង ។

ដានី:	អ៊ំហើយពីណាមួយទៀតមិញ?

សាម៉េត:	ឯម សារិន ។

ដានី:	ត្រពាំងប្រាសាទ?

សាម៉េត:	ត្រពាំងប្រាសាទ យូ សយ មានទាវ ទុំ, ទុំ ភាព, មែន សួន ។

ដានី:	កាលហ្នឹងឃុំទទួលរួមពីណាគេ?

សាម៉េត:	ឃុំ?

ដានី:	ឃុំត្រពាំងប្រាសាទ?

សាម៉េត:	បើនិយាយឃុំតែម្តងគឺ យូ សយ ។ ទុំ ហើយនិងភាព ជាប់គណៈកម្មាធិការរួម ។

ដានី:	ទុំ ហើយ?

សាម៉េត:	ភាព ។

ដានី:	អូរស្មាយ?

សាម៉េត:	អូរស្មាយមានបងស៊ី ហើយកេត សឿង មេឃុំរាល់ថ្ងៃ ដូចតែប៉ុណ្ណឹង ខ្ញុំចាំតែប៉ុណ្ណឹង ។

ដានី:	កេត សឿង រាល់ថ្ងៃគាត់មេឃុំអូរស្មាយដែរ?

សាម៉េត:	បាទ!

ដានី:	យូ សយ?

សាម៉េត:	យូ សយ ហ្នឹងនៅត្រពាំងប្រាសាទ ។

ដានី:	នៅត្រពាំងប្រាសាទឥឡូវគាត់នៅធ្វើអីដែរ?

សាម៉េត:	ឥឡូវគាត់រ៉ៃត្រេតហើយ ។

ដានី:	ចុះទុំ ហើយនិងភាព?

សាម៉េត: គាត់រ៉ឺត្រែតដូចគ្នា ។

ដានី: ចុះផ្លូវ ពីណាគេដឹបូង?

សាម៉េត: ផ្លូវ ដូចប្របូកប្របល់ អត់ច្បាស់ទេ វាភ្លេច ។

ដានី: ៩១ យើងចាប់ផ្តើមបង្កើតអីចឹងយ៉ាងម៉េច យើងចាប់ផ្តើមបង្កើតជាឃុំ យើងគ្រួសត្រាវចាប់ផ្តើមយ៉ាងម៉េចខ្លះទៅ មុនដំបូងយើងចាប់ផ្តើមកកើតភូមិហ្នឹង ប្រជាជនត្រូវធ្វើអី? រកស៊ី ក៏យ៉ាងម៉េច? ឬនៅកងទ័ពត្រូវមានរបប មានអាហារដដែលបន្ទាប់ពីឆ្នាំ៩១ហ្នឹងមក?

សាម៉េត: ដល់ឆ្នាំ១៩៩១ ចាប់រៀបចំបែកគ្នាតាមភូមិ ដូចខ្ញុំបញ្ជាក់ខាងដើម គ្រួសារកងទ័ព និងកងទ័ពនៅក្រោមគឺចាប់ផ្តើមដោះស្រាយសេដ្ឋកិច្ចជីវភាពខ្លួន ។ មានស្រូវ អង្ករ ខោអាវស្បៀកពាក់ ថ្នាំពេទ្យ សំរាប់ទិញដូរហើយ ។

ដានី: មានខោអាវ ស្បៀកពាក់ទិញដូរ តែយើងចាប់ផ្តើមធ្វើស្រែ ចំការខ្លួនឯង ផ្គត់ផ្គង់ខ្លួនឯងឬនៅតែអង្គភាពផ្គត់ផ្គង់?

សាម៉េត: ផ្គត់ផ្គង់ខ្លួនឯង ។

ដានី: ចាប់ពី៩១?

សាម៉េត: បាទ!

ដានី: ចាប់ពី៩១ យើងអត់ទាន់បានសន្តិភាពទេ?

សាម៉េត: នៅ ។

ដានី: នៅយ៉ាងម៉េចខ្លះអ៊ំអាចរៀបរាប់កន្លែងហ្នឹង?

សាម៉េត: ផ្នែកខាងប្រុសៗមួយចំនួនទៅសមរភូមិ ឯកំលាំងមួយចំនួននៅជាមួយគ្រួសារកងទ័ពនាំគ្នាកាប់ចំការដាំស្រូវ ពីព្រោះកាលហ្នឹងគឺថាផ្តាច់ជំនួយអស់ហើយ អត់មានថវិការ ធ្វើស្រែហូបខ្លួនឯង បានលុយកាក់មកដោះដូរទិញជាខោអាវស្បៀកពាក់ ថ្នាំពេទ្យនៅមានខ្លះ ។

ដានី: អីចឹងពេលហ្នឹងនៅទៅសមរភូមិនៅឡើយទេ?

សាម៉េត: បាទ!

ដានី: ប្រុសៗទៅសមរភូមិ ហើយក្រោយមកពេលបោះឆ្នោត៩៣ កងទ័ពរាជរដ្ឋាភិបាលមានចុះមកដល់ខាងហ្នឹងអីយ៉ាងម៉េចដែលកាលហ្នឹង?

សាម៉េត: ឆ្នាំសម្តេចនាយកគាត់មានប្រសាសន៍មកអន្លង់វែងខ្ញុំអត់បានចាំ ។

ដានី: គាត់ថាម៉េច?

សាម៉េតៈ គាត់មកដល់កន្លែងអន្លង់វែងគឺមកអត់ឃើញមនុស្សទេ តែទៅវិញវៃតាមក្រោយ គាត់មានប្រសាសន៍ថាគាត់មកអន្លង់វែង មកដល់គឺឆ្នាំហ្នឹងតែម្តង ខ្ញុំមិនបានចាំឆ្នាំ មកដល់មួយសារ កាលមុនអត់ដែលមកទេ ។

ដានីៈ សម្តេចនាយកគាត់មកហើយគាត់មានប្រសាសន៍ថាម៉េច?

សាម៉េតៈ គាត់ឡើងមកវៃនៅអន្លង់វែង ។

ដានីៈ គាត់ថាគាត់ឡើងមកវៃ?

សាម៉េតៈ បាទ! តាមគាត់មានប្រសាសន៍ ។

ដានីៈ ថាកងទ័ពគាត់មកវៃ ឬគាត់មកផ្ទាល់?

សាម៉េតៈ កងទ័ពគាត់មកវៃ គាត់បញ្ជាមកតាមក្រោយដែរ ។

ដានីៈ កងទ័ពគាត់ឡើងមកវៃប្រាប់ថាអត់មានមនុស្សទេ ស្រាប់តែកងទ័ពដកទៅវិញ ស្រាប់មនុស្សវៃ ។

សាម៉េតៈ របៀបបំបែកកំលាំង វៃឈ្លប ។ មកអត់ឃើញតែទៅវិញវៃតាមក្រោយ ។

ដានីៈ ដល់ពេលមកនៅឆ្នាំ៩១មកនៅមានផ្លាស់ប្តូរភូមិ-ឃុំទៅនេះ ទៅនោះ ឬនៅជាប់រហូត?

សាម៉េតៈ ផ្លាស់ខ្លះ ។

ដានីៈ យ៉ាងម៉េចខ្លះទៅ?

សាម៉េតៈ ផ្លាស់ ខាងព្រះប្រឡាយថ្មីដកទៅនៅព្រះប្រឡាយចាស់វិញមានពីរ ហើយពួក៨១៧ដកមកនៅបាក់អន្លង់នេះ ឯទំនប់ដាច់ជាកន្លែងចាស់របស់គេ ត្រពាំងប្រាសាទកន្លែងចាស់របស់គេ អូរស្មាយហើយនិងផ្លូវវាងនៅជាប់គ្នា ផ្លូវនៅភូមិចាស់របស់គេ អូរស្មាយមួយចំណែកធំគឺនៅអូរស្មាយ មួយចំណែកតូចនៅខាងក្រៅ ។

ដានីៈ តែមូលដ្ឋានតំបន់នេះមុនយើងចុះមកនៅអត់មានមនុស្សធ្លាប់រស់នៅហ្នឹងទេ?

សាម៉េតៈ អត់មានទេ ។

ដានីៈ កន្លែងណាខ្លះដែលធ្លាប់មានមនុស្ស មានប្រជាជនធ្លាប់រស់នៅមុនយើងចូលមក? ដីត្រពាំងប្រាសាទយើង?

សាម៉េតៈ អានេះឃើញជាភូមិសាស្រ្តទេ មើលដើមស្វាយធំៗឃើញផ្លូវមួយ ។

ដានីៈ មានផ្លូវមួយ ។

សាម៉េតៈ ហើយអន្លង់វែងពីរ យើងមើលតាមភស្តុតាងដែលមាននៅកន្លែង ។ ដូចជាដើមស្វាយធំៗបានន័យថាជីនាន់មុនយើងហើយ ។

ដានី: ដូចជាអូរស្វាយ, ទំនប់ដាច់, បាក់អន្លង់, ព្រះប្រឡាយ, ត្រពាំងប្រាសាទ អត់ដែលមានមនុស្សរស់នៅទេ?

សាម៉េត: អត់ដែរ ។

ដានី: គ្រាន់ត្រពាំងប្រាសាទមានប្រាសាទតាំងពីដើមមក?

សាម៉េត: នៅនេះ តែអត់មានមនុស្សទេ ។ នៅវត្តមានប្រាសាទ ។

ដានី: មានប្រាសាទតែពីមុនមកអត់មានមនុស្សរស់នៅ?

សាម៉េត: អត់មានទេ ។

ដានី: អ៊ំពេលឆ្នាំ៩១យើងមានសង្គ្រាម ពេលមានហ្នឹងយើងអត់រត់ចោលផ្ទះ យើងនៅហ្នឹងរហូត ឬមានរត់ទៅណាទៅណីទៀត?

សាម៉េត: អត់មានរត់ទៅណាទៀតទេ ព្រោះដឹងថានោះឡើងមកជម្លៀសទៅលើភ្នំ ក្នុងក្របខណ្ឌដីខ្មែរ ។

ដានី: ទៅធ្វើផ្ទះនៅលើភ្នំទៀត?

សាម៉េត: អត់ទេ ទៅគ្រាន់តែធ្វើជំរំតូចៗហើយ ដល់ពេលសភាពការណ៍ស្ងប់ទៅចុះមកនៅកន្លែងភូមិដដែល ។

ដានី: អីចឹងច្រើនដងដែលអត់?

សាម៉េត: វាមានក្នុងមួយឆ្នាំម្ដង ជួនកាល២-៣ឆ្នាំម្ដង វាអត់ជាប់ ។

ដានី: មួយឆ្នាំ១-២ដង?

សាម៉េត: វាអត់ទៀង អាហ្នឹងទី១តាមយើងហៅថាទឹកដី ឬធាតុអាកាស ឧបមាថាភ្លៀងខ្លាំងខាងមុខចល័តអត់រួចទៅក៏មកអត់រួច ឆ្នាំណារាំងក៏ចល័តមកបានទៅ តែបើភ្លៀងជាប់ក៏មកអត់រួច ហើយខាងនេះក៏អីចឹង តែភាគច្រើនអត់គេចទេ គ្រាន់តែចេញពីផ្ទះទៅព្រៃ ព្រោះកាលជំនាន់នោះព្រៃពេញទាំងអស់ ដូច្នេះមិនសាយធ្វើអីកើតទេ គ្រាន់តែចេញពីផ្ទះបាត់ហើយ ។

ដានី: នៅអន្លង់វែងចាប់ផ្ដើមបែកបាក់ផ្ទៃក្នុង ដូចថាក្រុមតាប៉ុលពត ក្រុមតា០៥ ហើយនិងខាងតាម៉ុកចាប់ផ្ដើមបែកបាក់ អ៊ំដឹងមូលហេតុយ៉ាងម៉េចបានចាប់ផ្ដើមមានការបែកបាក់គ្នាអីចឹង?

សាម៉េត: ខ្ញុំអត់ច្បាស់សុំទោសផងអត់ច្បាស់កន្លែងហ្នឹង ។

ដានី: ដូចថាមានបែកបាក់ហើយចាប់ផ្ដើមបែកបាក់ពួក ដូចថាលែងសូវទុកចិត្តគ្នា ខាងនេះចេះខាងនោះចុះ វាដើមហេតុអីដំបូងមកពីយ៉ាងម៉េច?

សាម៉េតៈ អត់ច្បាស់ទេកន្លែងត្រង់ហ្នឹង ព្រោះលឺសួរថាបែកបាក់គ្នា ហើយបានមានកំលាំងមួយចំនួន ទៅផ្សាភ្ជាប់ជាមួយខាងក្នុងនោះបានបែក ឯរឿងធំដុំខ្ញុំមិនច្បាស់ ។

ដានីៈ ដូចជាការស្លាប់របស់តាសុន សេន យ៉ាងម៉េចដែរមូលហេតុ?

សាម៉េតៈ អាហ្នឹងរឹតតែលែងច្បាស់ទៀត ។

ដានីៈ ដូចខាងអន្លង់វែងទៅខាងតា០៥ ខាងតាប៉ុល ពត បញ្ជាឲ្យតា០៥ឲ្យទៅសម្លាប់ វាពាក់ព័ន្ធមានការមិនទុកចិត្តគ្នាយ៉ាងម៉េច ហើយមួយចំនួនថាមិនមែនទេ ល្បិចមកពីខាងតាម៉ុកទេ ដូចថាចង់ទម្លាក់កំហុសឲ្យតា០៥?

សាម៉េតៈ កន្លែងហ្នឹងខ្ញុំអត់ច្បាស់ទេ សុំអត់មានមតិចុះ ។

ដានីៈ ក្រោយៗមកទៀតយើងបែកបាក់មែនទែន យើងវៃគ្នា ដូចថាវៃគ្នា ហ្នឹងយ៉ាងម៉េចដែរ អ៊ំនៅខាងណា?

សាម៉េតៈ ឃើញចល័តចុះ ចល័តឡើង ខ្ញុំនៅខាងត្រពាំងប្រាសាទ តែដោយខ្សែកខ្ញុំនៅប៉ែកខាងកើត នៅស្រុកត្រពាំងប្រាសាទ និងអន្លង់វែងនៅមួយកន្ទុប បានជាខ្ញុំមិនហ៊ានមតិក្នុងហ្នឹងហាក់ដូចជាមិនឃើញមានអី ដូនកាលក៏គេអត់ឲ្យយើងដឹង យើងចេះតែរស់នៅធម្មតាគ្រប់គ្រងធម្មតា ដល់មានប៉ះពាល់គ្នាឃើញចល័តចុះ ចល័តឡើង ឲ្យវៃគ្នាអត់មានវៃទេពីព្រោះវៃគ្នាខាងកើត អត់មានរៀបចំកំលាំងយោធាទេនៅធម្មតា ហ្នឹងខាងស្រុកត្រពាំងប្រាសាទ ហើយខាងអន្លង់វែងមានរៀបចំកំលាំងកង់ទ័ពខ្លះ ដើរចល័តចុះ ចល័តឡើង ហើយដល់មកឃើញសុទ្ធតែស្គាល់គ្នា អាហ្នឹងស្អីទេអញទៅផ្ទះវិញឃើញតែប៉ុណ្ណឹង ។

ដានីៈ ខ្លះទៅនៅខាងអន្លង់វែងតាម៉ុក ថាប៉ុល ពត ក្បត់ ដល់ពេលខាងនេះថាតាម៉ុក ក្បត់ បើតាមជាក់ស្តែងអ្នកណាក្បត់អ្នកណា? ឬយ៉ាងម៉េចបានទៅជាអីចឹង?

សាម៉េតៈ ខ្ញុំអត់បានដឹងទេ វាហួសការដឹងរបស់ខ្ញុំ ។

ដានីៈ ដូចការកាត់ទោសតាប៉ុល ពតនៅលើភ្នំ អ៊ំមានបានទៅចូលរួម មានដឹងទេ?

សាម៉េតៈ អត់បានទៅទេ ។

ដានីៈ យោបល់អ៊ំវិញយ៉ាងម៉េចដែរ ហើយដោយសារអ្នកណាខុស អ្នកណាត្រូវ? បើជាយោបល់អ៊ំ?

សាម៉េតៈ ត្រង់កន្លែងហ្នឹងខ្ញុំមិនហ៊ានមានមតិទេ ព្រោះអត់ច្បាស់ទាំងអស់ ។ បើថាតាម៉ុក ត្រូវក៏មិនដឹង ថាប៉ុល ពត ក៏មិនដឹង បើអត់ដឹងសាច់រឿង ។ បើខ្ញុំថាតាម៉ុក ត្រូវ ក្រែងមានចំណុចអីគាត់ខុសខ្ញុំអត់ដឹង បើថាប៉ុល ពត ត្រូវ ក្រែងគាត់មានចំណុចអីគាត់ខុសខ្ញុំអត់ដឹង ខ្ញុំសរុបខ្ញុំអត់ហ៊ានមានមតិទេ ។

ដានីៈ អ៊ំទាក់ទងនឹងអ៊ំៗវិញ អ៊ំស្គាល់តាម៉ុក ច្បាស់ទេ?

សាម៉េតៈ ស្គាល់ច្បាស់នៅនេះទេ ។

ដានីៈ ស្គាល់នៅណា?

សាម៉េតៈ នៅអន្លង់វែង ។

ដានីៈ បានជួបគាត់ បាននិយាយគាត់ ដូចថានៅកៀកគាត់ដែរ?

សាម៉េតៈ អត់បានកៀកទេ ធ្លាប់ជួបគាត់បាន២ដងនៅអន្លង់វែង ។ ជួបហ្នឹងជួបធ្វើស្ពានអន្លង់វែង គាត់នៅឈរបញ្ជាធ្វើស្ពានអន្លង់វែង ។

ដានីៈ អ៊ំអ្នកធ្វើស្ពាន?

សាម៉េតៈ អត់ទេ ខ្ញុំអ្នកធ្វើដំណើរចុះឡើង ។ គាត់ថាឯងដើរទាល់តែជួយលើកថ្ម១-២ដុំដាក់សិនបានឲ្យទៅទៀត ព្រោះស្ពានៗដើរទាំងអស់គ្នា មិនមែនដើរតែអញទេ ឯងដើរទាំងអស់គ្នា អីចឹងឯងជួយលើកថ្ម២-៣ដុំដាក់សិន ។

ដានីៈ អ៊ំទៅជួយលើក?

សាម៉េតៈ ជួយព្រោះដឹងថាដើរទាំងអស់គ្នា ។

ដានីៈ បើអត់ជួយលើកអាចគាត់ខឹង?

សាម៉េតៈ ទេមិនដឹងទេ គ្រាន់តែក្នុងនាមយើងដឹងថាប្រើប្រាស់ទាំងអស់គ្នា ទៅជួយគ្នា ។

ដានីៈ អ៊ំមើលទៅអត្តចរិតគាត់មនុស្សយ៉ាងម៉េចដែរ តាម៉ុក?

សាម៉េតៈ ពិបាក អ្នកខ្លះថាគាត់តួងតាំងតិចទៅ ខ្ញុំពិបាកព្រោះអត់សូវបានស្គាល់ជិតស្និត និយាយរួមដឹកនាំធំៗខ្ញុំមិនសូវបានជិតស្និត ដល់អីចឹងវិនិច្ឆ័យអត់ត្រូវទេ មិនដឹងជាយ៉ាងណា ។

ដានីៈ អត់ដឹងពីអត្តចរិតគាត់ច្បាស់ទេ?

សាម៉េតៈ បាទ!

ដានីៈ ចុះតាសុន សេន ដែលស្គាល់គាត់ច្បាស់?

សាម៉េតៈ អត់ ។

ដានីៈ អត់ដែលទេ?

សាម៉េតៈ ព្រោះគាត់សុទ្ធតែថ្នាក់ធំៗ ។

ដានីៈ តាប៉ុល ពត?

សាម៉េតៈ ប៉ុល ពត ឃើញតាមរូបថត ។

ដានីៈ តានួន ជា, តាខៀវ សំផន?

សាម៉េតៈ ហ្នឹងហើយ ។

ដានី៖ អ៊ឺមាននៅសេសសល់ឯកសារ ដូចជារូបថត ឬឯកសារធ្លាប់រៀនសូត្រមានសេសសល់?

សាម៉េត៖ អត់ទេ។

ដានី៖ រូបថតអ៊ី?

សាម៉េត៖ អត់មានទេ។

ដានី៖ របស់របរប្រើប្រាស់?

សាម៉េត៖ របស់អត់ទេ ខោអាវស្លៀកពាក់ក៏អត់ដែរ។

ដានី៖ សៀវភៅអីរៀនសូត្រ?

សាម៉េត៖ អត់ នឹកឃើញអស់ជំនាន់ដុតចោលអស់ទៅ យកសៀវភៅថ្មីៗមក។

ដានី៖ អ៊ឺមុនហ្នឹងមានប្រសាសន៍យុទ្ធសាស្ត្រឈ្នះៗរបស់សម្ដេចអ៊ី អ៊ំនៅចាំថាយ៉ាងម៉េចយុទ្ធសាស្ត្រហ្នឹង ហើយចាប់ផ្ដើមយ៉ាងម៉េចដែរអ៊ំ អាចមានប្រសាសន៍ម្ដងទៀត?

សាម៉េត៖ ខ្ញុំគិតថាមាគ៌ាឈ្នះៗរបស់សម្ដេចនាយករដ្ឋមន្ត្រី ជាពិសេសសម្ដេចនាយក ហ៊ុន សែន ដែលលើកមាគ៌ាឈ្នះៗ ហើយមានចេញជាគោលនយោបាយ៣ខ សំខាន់ នេះជាមាគ៌ាដ៏ត្រឹមត្រូវមួយនាំឲ្យជាតិ ប្រជាជនដែលធ្លាប់បែកបាក់គ្នាកន្លងទៅ នាំឲ្យមកសន្តិភាពបាន ហើយខ្ញុំយល់ថាមាគ៌ានេះខ្លាំងជាងអាវុធឆ្ងាយណាស់ យើងបញ្ចប់សង្គ្រាមបានដោយគ្មានបង្ហូរឈាម ហើយភាគីម្ខាងទៀតគឺមករស់នៅជាមួយរាជរដ្ឋាភិបាលដោយសុទ្ធចិត្តមិនមានការបង្ខំ យល់ថាត្រូវតែបញ្ចប់សង្គ្រាម ឈប់ទាស់ទែងគ្នាបានមានការអភិវឌ្ឍន៍ប្រទេស នេះជាចំណុចសំខាន់ ហើយនឹងមានជំនឿជឿជាក់ថាសន្តិភាពនឹងមាននៅលើទឹកដីកម្ពុជាជារៀងរហូត ព្រោះយើងដឹងថា ការផ្សះផ្សារជាតិ រួបរួមជាតិរស់នៅក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ ប្រទេសជាតិយើងសំរាប់អភិវឌ្ឍន៍ តាមការយល់របស់ខ្ញុំមិនអាចវិលត្រឡប់មកខាងក្រោយវិញទេ។

ដានី៖ ដែលយើងបានសន្តិភាពពេញលេញពីឆ្នាំ?

សាម៉េត៖ ១៩៩៨។

ដានី៖ កាលហ្នឹងយ៉ាងម៉េចដែរ កាលហ្នឹងមុននឹងបានសន្តិភាពពេញលេញ ម្ខាងទៅចុះចូលជាមួយរដ្ឋាភិបាល ខាងតាម៉ុក គាត់ទៅនៅលើភ្នំ ទៅនៅជំរំភូណាយ ហើយអ៊ំកាលហ្នឹងទៅខាងណា?

សាម៉េត៖ មកខាងនេះ។

ដានី៖ ខាងណា?

សាម៉េតៈ ខាងឈ្នះៗ ។

ដានីៈ ខាងឈ្នះៗ ទៅខាងណា?

សាម៉េតៈ មកខាងស្រុកត្រពាំងប្រាសាទ ម្ខាងគេទៅខាងនោះ តែខ្ញុំមកខាងនេះ ។

ដានីៈ អន្លង់វែងម្ខាងទៅខាងភូណយ ហើយម្ខាងទៅបាយតាប់ ហើយខាងនេះយើងទៅខាងទំនប់ដាច់ ។

សាម៉េតៈ អាហ្នឹងចែកជា៣ អន្លង់វែងមួយចំនួនទៅបាយតាប់ ឯខ្ញុំត្រពាំងប្រាសាទមកទំនប់ដាច់នេះ ហើយមួយចំនួនតូចទៀតទៅភូណយ តែផ្នែកខាងស្រុកត្រពាំងប្រាសាទគឺមកនេះទាំងអស់ ហើយខាងអន្លង់វែងទៅបាយតាប់ ។

ដានីៈ ហើយកាលហ្នឹងម៉េចអ៊ីគិតថាអត់ទៅតាមតាម៉ុក ទៅខាងភូណយ?

សាម៉េតៈ តាមខ្ញុំដឹងខ្លះប៉ែកខាងនេះ មានឯកឧត្តម ជុំ ជាតិ, ឯកឧត្តម ជា កែវ មានបងៗមួយចំនួនទៀតទៅខាងព្រះវិហារ ក៏បានផ្សាយតៗគ្នាពីគោលនយោបាយឈ្នះៗ ។

ដានីៈ ផ្សាយពីនយោបាយឈ្នះៗហ្នឹង?

សាម៉េតៈ នយោបាយឈ្នះៗ ។

ដានីៈ ដំបូងគាត់ផ្សាយនយោបាយឈ្នះៗមែន តែយើងអត់ទាន់ដឹង យើងជឿដែរ?

សាម៉េតៈ ការជឿវាមានចំណុចសំខាន់ពីក្រោម ទី១គាត់ទៅខាងព្រះវិហារជាមួយរាជរដ្ឋាភិបាល ហើយគាត់ហ៊ានសន្យាថាចេះមួយ ចុះពីរ ។ ហើយយល់ឃើញថាគាត់ក៏ជាអ្នកធ្លាប់រួមរស់ជាមួយ គាត់មិនដែលសម្លាប់យើងទេ នាំឲ្យកំលាំងខាងនេះមកតាមគាត់ទាំងអស់ ។

ដានីៈ មកតាមគាត់ទាំងអស់ទៅពីឆ្នាំ៩៨?

សាម៉េតៈ បាទ!

ដានីៈ សម្ដេចហ៊ុនសែន ធ្លាប់អញ្ជើញមកដល់នេះអត់?

សាម៉េតៈ ឈប់ខ្ញុំមើលសិន មកដល់ស្រុកសន្តិភាពគាត់មកកន្លែងអន្លង់វែង ខាងជើងអន្លង់វែងកន្លែងទីលានមួយ ។

ដានីៈ យើងពីត្រពាំងប្រាសាទ-អន្លង់វែង ទៅជួបគ្នាហ្នឹង?

សាម៉េតៈ បាទ!

ដានីៈ ពេលផ្ដាច់ខ្លួនហ្នឹង?

សាម៉េតៈ បាទ! គាត់អញ្ជើញមកជាំក្សាន្ត អញ្ជើញកំលាំងទៅស្ដាប់ប្រសាសន៍របស់គាត់នៅស្រុកជាំក្សាន្ត សំណេះសំណាលជាមួយប្រជាពលរដ្ឋ ។

ដានី៖ ដល់ពេលយើងសមាហរណកម្មហើយឆ្នាំ៩៨ ត្រពាំងប្រាសាទយើងឈ្មោះជាស្រុកពេញសិទ្ធិមែនទែនឆ្នាំប៉ុន្មានទៅ?

សាម៉េត៖ តាមខ្ញុំចាំដូចជាឆ្នាំ២០០០ ។

ដានី៖ ដូចថាកាលមុនយើងបែកចែកមកអីចឹងថាគ្រប់គ្រងស្រុកនេះពីណា១ ដល់ពេលក្រោយមកសមាហរណកម្មយើងមិនមានពេញសិទ្ធិជាអភិបាលស្រុក ។

សាម៉េត៖ បេះហ្នឹងចែកជាពីរ កាលជំនាន់មុនវានៅក្រៅរដ្ឋធម្មនុញ្ញ ដល់មកក្នុងរដ្ឋធម្មនុញ្ញទទួលស្គាល់ជាផ្លូវការតាមខ្ញុំចាំអាច២០០០-២០០១ ។

ដានី៖ ឆ្នាំ២០០០?

សាម៉េត៖ បាទ!

ដានី៖ ដល់ឆ្នាំ២០០០យើងចាប់ផ្តើមទទួលផ្លូវការ នៅត្រពាំងប្រាសាទយើងពីណាគេអភិបាលស្រុកដំបូង?

សាម៉េត៖ ជុំ ជាតិ ។

ដានី៖ ម៉េចបានគាត់អត់ទៅនេះ គាត់នៅធ្វើជាអភិបាលស្រុក ដោយសារសម្តេចតែងតាំងគាត់ឲ្យធ្វើអភិបាលស្រុក ឬក៏គាត់ចង់?

សាម៉េត៖ ត្រង់កន្លែងហ្នឹងខ្ញុំអត់ច្បាស់ ។

ដានី៖ អីចឹងអភិបាល ជុំ ជាតិ ចុះអភិបាលរងមានប៉ុន្មាននាក់?

សាម៉េត៖ អុង វ៉ែន ។ មួយទៀតស្លាប់ឈ្មោះ ជឿន តែខ្ញុំភ្លេចឈ្មោះត្រកូលគាត់ ។

ដានី៖ ឈ្មោះ ជឿន?

សាម៉េត៖ យ៉ោក ជឿន ។

ដានី៖ គាត់ស្លាប់ហើយ?

សាម៉េត៖ ស្លាប់ហើយ ។

ដានី៖ ស្លាប់យូរនៅ?

សាម៉េត៖ យូរដែលហើយ ។

ដានី៖ យ៉ាងម៉េចបានគាត់ស្លាប់?

សាម៉េត៖ កាលហ្នឹងដូចទៅត្រង់ណាលីសូរគេប្ញូន់ ទៅក្នុង ដូចទៅទិញគោសំរាប់ផ្តល់ឲ្យកន្លែងអគ្គភាពសំរាប់ធ្វើជាកំលាំងអូសទាញ ។

ដានី៖ កាលហ្នឹងមាន៣នាក់ហ្នឹងទេ?

សាម៉េត៖ បាទ! តាមខ្ញុំចាំ ។

ដានី៖ អភិបាល ហើយនិងអភិបាលរង២ ។

សាម៉េត៖ បាទ!

ដានី៖ ពីឆ្នាំ២០០០ ដល់ឆ្នាំពីរពាន់ប៉ុន្មានទៅឯកឧត្តមជុំ ជាតិ ។

សាម៉េត៖ ទេ មិនមែន២០០០ទេ ដូចជាតាំង៩៨មក មែនហើយ២០០០-២០០៥ ។

ដានី៖ ដល់ពេលយ៉ោក ជឿន គាត់ស្លាប់ទៅឡើងពីណាជំនួសគាត់?

សាម៉េត៖ សៅ ថាន ។

ដានី៖ ស្លាប់យូរហើយ ឬទើបតែស្លាប់ យ៉ោក ជឿន?

សាម៉េត៖ ស្លាប់យូរហើយ ។

ដានី៖ គាត់កាន់បានយូរទេ?

សាម៉េត៖ ដូចជាបាន២ឆ្នាំមិនដឹង ។

ដានី៖ ដល់ពេលចាប់ពី២០០៥មកអ្នកណាឡើងជំនួស អភិបាលស្រុក អភិបាលរង?

សាម៉េត៖ មានប៉ុន ពិន ។

ដានី៖ អភិបាលពីណាគេ?

សាម៉េត៖ ចាប់ពីឆ្នាំ២០០៥ទៅ វ៉ាន់ កុសល ។

ដានី៖ វ៉ាន់ កុសល គាត់អត់មាននៅក្នុងចំណោមអភិបាលរងទេកាលពីអណត្តិទី១?

សាម៉េត៖ អត់ទេ នៅក្នុងប្រធានសាលាស្រុក ។

ដានី៖ ប្រធានរដ្ឋបាល?

សាម៉េត៖ កាលហ្នឹងគេហៅប្រធានសាលាស្រុក ។

ដានី៖ ដល់ពេលអភិបាលរង?

សាម៉េត៖ អ៊ុង វ៉ែន ។

ដានី៖ អ៊ុង វ៉ែន គាត់នៅអភិបាលរងដដែល គាត់អត់បានឡើងអភិបាលទេ?

សាម៉េត៖ បាទ! ហើយបានមក សៅ ថាន មក ប៉ុន ពិន ។

ដានី៖ ប៉ុណ្ណឹង?

សាម៉េត៖ ឈប់ខ្ញុំរកនឹក ហ្នឹងនិយាយតែក្នុងអភិបាល ហើយដូចជា ហ៊ុន នៅ ។

ដានី៖ ឥឡូវគាត់ទៅណា ហ៊ុន នៅ?

សាម៉េត៖ គេផ្លាស់គាត់ទៅណាទេ ។

ដានី៖ គាត់អ្នកអតីតនៅហ្នឹងដែរ ឬគាត់?

សាម៉េត៖ អត់ទេ គាត់ផ្នែកខាងកំលាំងមកផ្សេង ។

ដានី៖ គាត់មិនមែនអ្នកអតីតអ្នកនៅជាមួយគ្នារបស់អ៊ំទេ?

សាម៉េត៖ ហើយឯម សារិន ហើយខ្ញុំ ។

ដានី៖ ឯម សារិន រងដែរ ហើយនិងពូគីម សាម៉េត ។ កាលហ្នឹងរងច្រើន ឬផ្លាស់ប្តូរ?

សាម៉េត៖ កាលហ្នឹងខាងលើសំរេចឲ្យរៀបចំអីចឹងតែម្តង ។

ដានី៖ រៀបចំរងមាន៦នាក់?

សាម៉េត៖ បាទ!

ដានី៖ ច្រើនណាស់កាលហ្នឹង ។ កាលពីអណត្តិទី១មានតែ២ទេ ។

សាម៉េត៖ ២-៣ហ្នឹង ។ ដល់អណត្តិទី២ ខាងលើរៀបចំឲ្យមានច្រើន ។

ដានី៖ វ៉ាន់ កុសល ពីឆ្នាំ២០០៥ដល់ឆ្នាំពីរពាន់ដប់ប៉ុន្មាន?

សាម៉េត៖ គាត់រ៉ឺត្រែតដូចជា២០១២មិនដឹង ២០១២ ឬ២០១៣ខ្ញុំអត់ច្បាស់ តែគាត់រ៉ឺត្រែត ហើយ ។

ដានី៖ ហើយអភិបាលស្រុកថ្មីឈ្មោះ?

សាម៉េត៖ ឈ្មោះគាត់ នៅ សំគាភរិទ្ធ ហ្នឹងលឺសូរ តែសរសេរពេញអត់ច្បាស់ដែរ ។

ដានី៖ នៅ សំគាភរិទ្ធ ឃើញគាត់សរសេរដាក់ក្នុងនោះ ។

សាម៉េត៖ ខ្ញុំមិនបានពិនិត្យច្បាស់ ។

ដានី៖ ដល់ពេល វ៉ាន់ កុសល គាត់រ៉ឺត្រែតឆ្នាំ២០១២ ចុះអ៊ុង វ៉ែន គាត់រ៉ឺត្រែតតាំងពីឆ្នាំ?

សាម៉េត៖ ដូច២-៣ឆ្នាំហើយ ។

ដានី៖ តែគេអត់មានជ្រើសរើសអភិបាលរងអីចូលថែមទេ?

សាម៉េត៖ អត់ទេ ។

ដានី៖ សៅ ថាន?

សាម៉េត៖ សៅ ថាន រ៉ឺត្រែតហើយ ។

ដានី៖ រ៉ឺត្រែតយូរនៅ ទើបថ្មីៗ?

សាម៉េត៖ ប្រហែលជាមួយឆ្នាំហើយ ។

ដានី៖ ប៉ុន ពិន?

សាម៉េត៖ ប៉ុន ពិន រ៉ឺត្រែតមុនខ្ញុំបន្តិច ។

ដានី៖ ហ៊ុន នៅ?

សាម៉េត៖ ហ៊ុន នៅ ដូចខ្ញុំបញ្ជាក់ថាគាត់ផ្លាស់ទៅ ។

ដានី៖ ផ្លាស់ទៅយូរនៅ?

សាម៉េតៈ　ផ្លាស់យូរដែលហើយ មកយុន សេរីរត្ន នេះ ។

ដានីៈ　លោកពូឯម សារិន?

សាម៉េតៈ　ឯម សារិន ក៏រ៉ីត្រែតដែលហើយ ។

ដានីៈ　រ៉ីត្រែតយូរនៅ?

សាម៉េតៈ　យូរដែលហើយ រ៉ីត្រែតតាំងពីជំនាន់រៀបចំក្រុមប្រឹក្សាស្រុក ។

ដានីៈ　អុំ?

សាម៉េតៈ　ខ្ញុំត្រូវរ៉ីត្រែតនៅខែ៦នេះ ។

ដានីៈ　ឥឡូវខាងអភិបាល នៅ សំតាភារិទ្ធិ គាត់អភិបាលស្រុក ហើយអភិបាលរង?

សាម៉េតៈ　ឈឹម ស៊ីវ៉ុធ ហើយស្តី សល់ ទេអភិបាលរងមួយទៀត ។

ដានីៈ　ឈ្មោះអីគេទៅ?

សាម៉េតៈ　ផុន ជាកុសល ហើយយុន សេរីរត្ន ។

ដានីៈ　តែ៣ហ្នឹងទេ?

សាម៉េតៈ　ត្រូវថែមនារីមួយទៀត តែខាងលើអត់ទាន់ឲ្យចាត់តាំង ។

ដានីៈ　ឈ្មោះអីគេ?

សាម៉េតៈ　នារី តែអត់ដឹង ។

ដានីៈ　អត់ទាន់មានសមាសភាពទេ?

សាម៉េតៈ　បាទ!

ដានីៈ　អីចឹងនៅឆ្នាំ២០១២នេះខាងគណៈអភិបាលស្រុក គឺគាត់ថ្មីៗទាំងអស់?

សាម៉េតៈ　បាទ!

ដានីៈ　ដូចថាក្រុមខាងអុំ ពូ ដែលជាអតីតពីមុនមកអស់ហើយ?

សាម៉េតៈ　បាទ!

ដានីៈ　អស់ដោយសារយើង?

សាម៉េតៈ　រ៉ីត្រែត ។

ដានីៈ　ដល់អាយុរ៉ីត្រែត?

សាម៉េតៈ　បាទ!

ដានីៈ　ប៉ុន្តែក្រុមអុំ ពូ រ៉ីត្រែតហើយតែយើងនៅខាង ។

សាម៉េតៈ　ជាក្រុមប្រឹក្សាស្រុក ។

ដានីៈ　អត់មាននៅក្នុងខាងអភិបាលស្រុកទៀតទេ ដោយសារវ័យ?

សាម៉េតៈ បាទ!

ដានីៈ រ៉ឺត្រែតអាយុចាប់ពីប៉ុន្មានទៅ?

សាម៉េតៈ មានតាមនេះរបស់វា ចាប់ពី៥៥, ៥៨, ៦០ ប្រភេទ៦០ ប្រភេទអនុមន្ត្រី, ប្រភេទ ៥៨ ប្រភេទមន្ត្រីក្រមការ ហើយប្រភេទ៥៥ លេខារដ្ឋបាល ។

ដានីៈ ថាំនះជាអភិបាលស្រុក?

សាម៉េតៈ ហ្នឹងជាអនុមន្ត្រីហើយ ។

ដានីៈ ហើយអភិបាលរង?

សាម៉េតៈ ជាមន្ត្រីក្រមការ ហើយថ្នាក់ការិយាល័យខ្លះជាលេខាធិការ ។

ដានីៈ នេះចាំបាច់ត្រូវតែរ៉ឺត្រែតតែម្ដង?

សាម៉េតៈ បាទ! ព្រោះច្បាប់ចែងអីចឹងហើយ យើងត្រូវតែអនុវត្តន៍ ។

ដានីៈ អ៊ីខ្ញុំបកទៅក្រោយបន្តិច មុនសមាហរណកម្ម ហើយនិងសមាហរណកម្មហើយ ជីវភាពរស់នៅមានការខុសគ្នាយ៉ាងម៉េចខ្លះដែលទៅ?

សាម៉េតៈ មុនសមាហរណកម្មបើគិតពីរឿងជីវភាព បើនិយាយការហូបចុកវាគ្រប់គ្រាន់ហើយ តែផ្នែកខាងជាការប្រើប្រាស់ ជារបស់របរអត់មានអី យ៉ាងច្រើនកន់តែប៉ុណ្ណឹង ហើយមានអាត្រាក់សំរាប់ភ្ជួរស្រែប៉ុណ្ណឹង នេះខ្ញុំនិយាយពីប្រវត្តិដើម ប៉ុន្តែបើនិយាយពីសមាហរណកម្មហើយ តាំងពីសមាហរណកម្មមកដល់កន្លែងនេះ មកដល់បច្ចុប្បន្នទិដ្ឋភាពវាប្លែក វាខុសគ្នាស្រឡះ បើមុនសមាហរណកម្មការទៅណា មកណាវាមានក្របខណ្ឌ វាមានព្រំដែន តែឥឡូវអត់ទេ ចូលក្នុងច្បាប់រដ្ឋធម្មនុញ្ញតែមួយ ហើយក្លាយជាប្រជាពលរដ្ឋសាមញ្ញធម្មតា ចង់ដើរហើរទៅណាបានតាមចិត្ត ។ ទី២ការប្រកបមុខរបរជីវភាពប្រចាំថ្ងៃផ្សេងៗទៀតយើងធ្វើដូចគ្មានលាក់កំបាំង ធ្វើដោយគ្មានខ្លាច ធ្វើបានពេញទីអាស្រ័យថាមានក្រគឺខ្លួនឯងជាអ្នកខំប្រឹង ហើយខ្ញុំក៏មិននឹកស្មានថាមានភ័ព្វវាសនាអីរហូតដល់មានឡានជិះ ។

ដានីៈ ដោយសារខ្ញុំធ្លាប់បានជួបឃើញមានទស្សនៈ អ្នកខ្លះគិតថាការពីមុនយើងរស់នៅយើងដឹងតែធ្វើការងារយើងមានរបបហូបចុកគ្រប់គ្រាន់ តែឥឡូវយើងបន្ទាប់ពីសមាហរណកម្មហើយយើងមានដី មានធ្លី យើងត្រូវតែធ្វើខ្លួនឯង យើងត្រូវតែប្រឹងប្រែង តែអ្នកខ្លះគាត់ធ្វើទៅមិនដឹងវាយ៉ាងម៉េច គាត់មានជីវភាពអត់សូវល្អ គាត់ក្រ ដល់ពេលអីចឹងទៅខ្លះគាត់គិតថាកាលពីមុនស្រួលជាង ឥឡូវមកធ្វើខ្លួនឯង ធ្វើបាន ធ្វើមិនបាន បើធ្វើមិន

បានទៅហូបចុកអត់គ្រប់គ្រាន់ មើលទៅលំបាក នេះតាមយោបល់លោកអ៊ីយ៉ាងម៉េចដែរ?

សាម៉េតៈ ការពិតខ្ញុំយល់ថារបបណាក៏ដូចរបបណាក៏ដូចរបបណា ព្រោះយើងត្រូវការរបបហ្នឹង ប្រជាពលរដ្ឋទូទាំងប្រទេសយើងត្រូវការរបបហ្នឹង ត្រូវការមានសិទ្ធសេរីភាព ការនេះថាយើងអត់សិទ្ធិសេរីភាព អត់មានសិទ្ធិធ្វើស្រែ អត់មានសិទ្ធកាន់កាប់ដីធ្លី អត់សិទ្ធិធ្វើនេះធ្វើនោះ តែឥឡូវសិទ្ធិសេរីភាពគេឲ្យហើយ អ្នកមានសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ អ្នកមានសិទ្ធិប្រកបមុខរបរស្របច្បាប់ ដាំដុះធ្វើស្រូវ ធ្វើចំការ ដាំដំណាំផ្សេងៗទាំងអស់ អត់មានចាំបាច់ធ្វើនេះ លើកលែងតែអ្នកឯងធ្វើខុសច្បាប់មួយគត់ ។

ដានីៈ អាហ្នឹងជាបញ្ហាមួយត្រឹមត្រូវ តែមានចំនួនទៀតដូចជាបញ្ហា ដូចឥឡូវហ្នឹងបញ្ហាច្រើនបញ្ហាដីធ្លី ដូចថាប្រជាពលរដ្ឋហើយនិងក្រុមហ៊ុន ឬអ្នកមានមួយចំនួន វាមានបញ្ហាដីធ្លីនេះមិនដឹងជាមូលហេតុអី តែវាមានបញ្ហាអីចឹង ជួនណាគាត់បន្ទោសថាគាត់បាត់បង់ដីធ្លីអីចឹងដែលធ្វើឲ្យគាត់អត់មានដី ធ្វើឲ្យគាត់ជីវភាពក្រីក្រ តែបើតាមអ៊ំនៅត្រពាំងប្រាសាទប្រជាជននៅត្រពាំងប្រាសាទម៉េចដែរ?

សាម៉េតៈ ប្រជាជនភាគច្រើនគឺបានមានកាតកម្មសិទ្ធអស់ហើយ តែនៅមានមួយចំនួនតិចទេ មានការប៉ះពាល់ដីធ្លីជាមួយក្រុមហ៊ុន យើងកំពុងតែដោះស្រាយហើយ ដូចជាឃុំត្រពាំងប្រាសាទមាន៧/៨គ្រួសារ យើងបានរៀបចំផ្ទេរត្បូលេខជូនគាត់អស់ហើយ ។

ដានីៈ គាត់យ៉ាងម៉េចដែរ គាត់ពេញចិត្ត គាត់សប្បាយចិត្តឬយ៉ាងម៉េច?

សាម៉េតៈ ក្រោយពីខ្ញុំមកនៅក្រុមប្រឹក្សាមកហាក់ដូចជាដាច់បន្តិច តែពេលប្រជុំរបស់ក្រុមប្រឹក្សាស្រុកមានអភិបាលចូលរួមគាត់រាយការណ៍ថាគាត់នឹងដោះស្រាយ រហូតដល់បញ្ហានេះស្ងប់មួយចំនួនហើយ ។ មានបញ្ហាពាក់ព័ន្ធដីធ្លីមានឃុំត្រពាំងប្រាសាទ ឃុំព្រះប្រឡាយនិងឃុំផ្លាវ អូរស្មាយប៉ែកខាងជើង តែការដោះស្រាយកន្លងទៅ ក្រុមនិស្សិតស្ម័គ្រចិត្តបានចុះមកវាស់វែងហើយ យើងបានដោះស្រាយហើយ ធម្មតាទេធ្វើម៉េចឲ្យបានគ្រប់ដណ្តប់ វាមានពេលវេលា ហើយបន្តរហូតមកដល់សព្វថ្ងៃវានៅមានគន្លឹកន្លាក់ខ្លះ តែឯកឧត្តមអភិបាលខេត្ត និងអភិបាលស្រុកចុះទៅដោះស្រាយជាហូរហែរហើយ ។

ដានីៈ មួយទៀតទាក់ទងពីសេរីភាពដូចថាក្នុងការគោរពទំនៀមទំលាប់ប្រពៃណី សាសនា កាលពីមុនយើងផ្តាច់ខ្លួន កាលពីជំនាន់៣ឆ្នាំ ហើយនិងក្រោយមកសមាហរណកម្មហើយពី៩៣មក យ៉ាងម៉េចដែរមានលក្ខណៈខុសគ្នាយ៉ាងម៉េចដែរ បើតាមអ៊ំបានឆ្លងកាត់មក ធ្លាប់រស់នៅ ធ្លាប់ធ្វើការទាំងពីរ ទាំងជំនាន់មុន ហើយឥឡូវ?

សាម៉េតៈ តាមខ្ញុំធ្លាប់ឆ្លងកាត់ក្នុងរបប បើនិយាយពីរបបវាចូលដល់ ទី១របបសង្គមរាស្ត្រ ទី២របបកម្ពុជាប្រជាធិបតេយ្យ និងទី៣ក្នុងសម័យបច្ចុប្បន្ន។ បើធ្វើការប្រៀបធៀបក្នុងរបបទាំង៣ជំនាន់នេះ បើនិយាយពីសិទ្ធិសេរីភាពក្នុងសម័យបច្ចុប្បន្នវាលើសលុបហួស ឧបមាថាសេរីភាពខ្លះអាចថាមានសិទ្ធិនិយាយស្តី អាចថាមានសេរីភាព តែសេរីភាពវាទៅជាចង់ចូលអាណាធិបតេយ្យមិនគិតការគោរពច្បាប់ ដែលរដ្ឋធម្មនុញ្ញចែងទេ ជួនកាលវាអត់។ ហ្នឹងខ្ញុំនិយាយផ្នែកមួយចំនួនដែលសេរីភាពវាហួស វាហៀរពេក តែតាមពិតខ្ញុំយល់ថាដូចជាគ្មានជំរើសណាក្រៅពីរបបបច្ចុប្បន្ននេះទេ នឹងផ្សះផ្សារជាតិ និងមានសន្តិភាពតទៅមុខទៀត នេះការយល់ផ្ទាល់ខ្លួន។

ដានីៈ តែយើងនិយាយសាមញ្ញវិញកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ពី៧៥-៧៩ ហើយក្រោយ៧៩-៩៨ សេរីភាពដូចអ៊ី ដូចបងប្អូនពូមីងផ្សេងៗទៀត សេរីភាពយើងអាចមានពេល អាចប្រតិបត្តិទៅតាម ព្រោះយើងកើតមកគ្រួសារយើងជាខ្មែរ អាចថាយើងគោរព មានបុណ្យ មានទានតាមប្រពៃណី ភ្ជុំបិណ្ឌ ចូលឆ្នាំ ទៅវត្ត ទៅជួបជុំបងប្អូន ធ្វើអីៗទៅតាមប្រពៃណីទំនៀមទំលាប់ ជំនឿរបស់យើង។ មុនហ្នឹងហើយនិងក្រោយវាយ៉ាងម៉េច ពីមុនវាយ៉ាងម៉េច?

សាម៉េតៈ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យអត់មានទេ អត់តែម្តង ឯសម័យមុនយើងមាន។

ដានីៈ ពេលអ៊ីមកតស៊ូនេះ?

សាម៉េតៈ ចង់និយាយពីសម័យសង្គមរាស្ត្រនិយមយើងមានពេញទីហើយ តែសម័យកម្ពុជាប្រជាធិបតេយ្យអត់មាន តែដោយឡែកយើងមើលបច្ចុប្បន្ននេះ បើនិយាយទៅវាមិនជាខុសត្រូវអីនឹងរបបជំនាន់មុនទេ សម័យឆ្នាំ១៩៧០មុន គ្រាន់តែយើងកែទំរង់ខ្លះឲ្យវាស្របនឹងសភាពការណ៍ជំនាន់នោះ តែការគោរពតាមប្រពៃណីរបស់ប្រជាពលរដ្ឋយើងដូចជាជំនឿសាសនាវាចងបងប្អូនណាគេត្រូវជឿសាសនាអីហ្នឹងតាមជាក់ស្តែង គ្រប់ជំនឿសាសនាដែលបងប្អូនជឿ ហ្នឹងទី១ ។ ទី២ តាមបច្ចុប្បន្ននេះយើងឃើញថា ដោយហេតុនៅតំបន់នេះជាតំបន់ឆ្ងាយជាងគេ ដាច់ស្រយាលដែលមិនមានសាសនាអីទី១ ឥឡូវពាសពេញទាំងអស់ វាស្របទាំងអស់គ្នា។

ដានីៈ ឥឡូវយើងមានសេរីភាព យើងចង់ជឿអីក៏បានដែរ កុំឲ្យតែបំពានទៅលើច្បាប់។

សាម៉េតៈ បាទ!

ដានីៈ តែកាលពីសម័យកម្ពុជាប្រជាធិបតេយ្យមិនមាន មូលហេតុអីបានមិនមាន ដូចអ៊ីធ្លាប់មានបទពិសោធន៍ យើងធ្លាប់បំរើការងារហ្នឹងដែរ?

សាម៉េតៈ អាហ្នឹងតាមមើលទៅដូចជាយោងតាមរបបសង្គម ។

ដានីៈ របបពេលហ្នឹងគេយល់ឃើញថាម៉េច?

សាម៉េតៈ យើងនិយាយឲ្យចំថារបបកុំមុយនីស្តវាតាមលទ្ធិកុំមុយនីស្ត អត់មានស្អីៗណាផ្សេងទៀត ជាជំនឿសាសនា ឬអបិយជំនឿ ។

ដានីៈ របបកុំមុយនីស្តខ្លះគេអាចឲ្យមានជំនឿដែរ គ្រាន់តែមានការរឹតត្បិត តែវាមាន ។ កាលពីរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ពី៧៩មកវាមានវត្ត មានលោក មានបុណ្យទាន មានភ្ជុំបិណ្ឌ តែក្នុងសម័យកម្ពុជាប្រជាធិបតេយ្យគឺអត់មានទេ?

សាម៉េតៈ អត់មាន លោកសង្ឃក៏អត់មាន អាចប្រារព្ធពិធីចូលឆ្នាំ និងភ្ជុំបិណ្ឌ តែអត់មានព្រះសង្ឃទេ ។

ដានីៈ ពិធីចូលឆ្នាំ និងភ្ជុំបិណ្ឌគេប្រារព្ធយ៉ាងម៉េច?

សាម៉េតៈ គេប្រារព្ធរបៀបកំសាន្តធម្មតា រាំវែកធម្មតាតាមប្រពៃណី តែគ្មានព្រះសង្ឃ គ្មានវត្ត ។

ដានីៈ តែកាលហ្នឹងគេមាននិយាយថា ម៉េចបានជាមិនបង្កើតឲ្យមានព្រះសង្ឃ បង្កើតឲ្យមានវត្ត ខ្លាចប៉ះពាល់អីយ៉ាងម៉េចដែរ?

សាម៉េតៈ កាលជំនាន់នោះខ្ញុំនៅល្ងមដែរ មិនសូវច្បាស់ តាមដឹងខ្លះទៅលទ្ធិខ្លះតាមបែបបទរបស់ថ្នាក់ដឹកនាំកំពូល បើគេថាឲ្យបង្កើត ឬមិនបង្កើតស៊ីសងខាងលើ ។

ដានីៈ តែអ៊ំៗ គ្រាន់ពួកគាត់ជាអ្នកព្រះពុទ្ធសាសនាដែរ គាត់គោរពដែរមើលទៅ?

សាម៉េតៈ អាហ្នឹងខ្ញុំអត់ច្បាស់ថាយ៉ាងណាទេ ព្រោះស្គាល់តាមរូបថត ។

ដានីៈ ក្នុងផ្នត់គំនិតដូចជាអ៊ំ ដូចជាអ្នកផ្សេង អ៊ំៗ ពូ មីង របបគេទៅអីចឹង យើងបំភ្លេចអាហ្នឹងចោលដែលឬក៏យ៉ាងម៉េច? ដោយសាររបបទៅអីចឹងហើយ យើងឈប់គិតឈប់នឹកនាទាក់ទងរឿងប្រពៃណី ទំនៀមទំលាប់សាសនា កាលហ្នឹងយើងបំភ្លេចចោល ឬយ៉ាងម៉េច?

សាម៉េតៈ ប្រជាពលរដ្ឋយើងត្រូវការ តែអត់ដឹងធ្វើម៉េច ។

ដានីៈ យើងចង់ដែរ យើងចង់ធ្វើនឹកឃើញដែរ ។

សាម៉េតៈ តែអត់ដឹងធ្វើម៉េច ។

ដានីៈ តែក្រោយមក ដល់ពេលឥឡូវយើងសមាហរណកម្មហើយ យើងអាចធ្វើតាមចិត្ត ។ ពេលធ្វើសមាហរណកម្មហើយ យើងមានសិទ្ធិសេរីភាព បងប្អូនអ៊ំពូមីងដែលរស់នៅត្រពាំងប្រាសាទយើងយ៉ាងម៉េចដែរ? យើងចាប់ផ្តើមធ្វើម៉េចខ្លះទៅ ទាក់ទងរឿងប្រពៃណី សាសនា?

សាម៉េតៈ	រឿងប្រពៃណី ព្រះពុទ្ធសាសនា ពាក់ព័ន្ធដូចជាវត្តអារាម ជំនឿផ្សេងៗដែលគាត់ជិតដាមពីមុនមក គាត់ចាប់ផ្ដើមរំលឹក និងចាប់ផ្ដើមអនុវត្តន៍សារជាថ្មី ស្របនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ខ្ញុំគិតថានិយាយសាមញ្ញខ្ញុំទៅដូចជាគ្មានផ្លូវណា គ្មានរបបត្រូវដើរផ្លូវណាក្រៅពីបច្ចុប្បន្ននេះទៅបានទេ ព្រោះខ្ញុំពិចារណាមុនឆ្នាំ១៩៧០ ក្រោយពីសង្រ្គាមជាមួយអាមេរិកចប់ មកសម័យ៣ឆ្នាំ ឯក្នុងសម័យរដ្ឋកម្ពុជាខ្ញុំមិនយល់ តែអូនបង្ហើបថាមានសាសនា អាហ្នឹងវារឿងមួយ តែខ្ញុំគិតថាទាំងប៉ុន្មានជំនាន់ ទាំងប៉ុន្មានរបបនេះហើយដែលយើងដំណើរការបច្ចុប្បន្ន ហើយខ្ញុំគិតថាមិនដឹងជាទៅខាងណាទៀត ។

ដានីៈ	អ៊ំ ពូ មីងដែលជាអតីតដូចអ៊ំដែរ បន្ទាប់ពីគាត់មានសេរីភាព យើងមានសាសនា ភាគច្រើនភាគពួកគាត់កាន់ទំនៀមទំលាប់ ព្រះពុទ្ធសាសនាដដែល ឬមានមួយចំនួនគាត់ទៅខាងសាសនាគ្រិស្ត ឬសាសនាផ្សេងៗទៀតមានទេ?

សាម៉េតៈ	ភាគច្រើនលើសលប់នៅខាងប្រពៃណី ជាពិសេសខាងព្រះពុទ្ធសាសនា ខាងយេស៊ូគ្រិស្ដដូចជាមិនទាន់លឺ មិនទាន់ចេញមុខឲ្យច្បាស់ មិនទាន់ច្បាស់ ភាគច្រើនលើសលប់ ។

ដានីៈ	ព្រះពុទ្ធសាសនា?

សាម៉េតៈ	ព្រះពុទ្ធសាសនា ។

ដានីៈ	វត្តអារ៉ាម ព្រះសង្ឃយើងចាប់ផ្ដើមមកកើត ចាប់ផ្ដើមមាននៅត្រពាំងប្រាសាទយើងចាប់ពីឆ្នាំណាមក?

សាម៉េតៈ	ចាប់ពីឆ្នាំ២០០១ មានវត្តត្រពាំងប្រាសាទមុនគេ ហើយទៅវត្តទំនប់ដាច់ទី២ ឥឡូវតាមខ្ញុំចាំខ្លះ ដឹងខ្លះ វត្តជាផ្លូវការមានហើយ ប្រហែលជា១៥វត្ត ។

ដានីៈ	១៥វត្តក្នុងត្រពាំងប្រាសាទយើង?

សាម៉េតៈ	បាទ!

ដានីៈ	ហើយចុះព្រះសង្ឃដែលមកគង់នៅក្នុងវត្តដំបូង ដូចថាកូនចៅរបស់អ៊ំ ពូ មីងអ្នកស្រុកអ្នកភូមិយើងហ្នឹង ឬក៏ព្រះសង្ឃគាត់និមន្តមកពីខាងណាគង់នៅវត្តដំបូង?

សាម៉េតៈ	ព្រះសង្ឃជាឪពុករបស់លោកអតីតខ្មែរក្រហមម្នាក់ហ្នឹងគាត់អញ្ជើញមក ដល់អញ្ជើញមកគាត់វ័យចាស់បន្តិច ហើយដល់ឃើញកូននៅហ្នឹង សំខាន់សមាហរណកម្មហើយយើងមានសិទ្ធិសេរីភាពរកស៊ីអី ចង់និយាយថាមិនគិតរឿងអសន្តិសុខទេ ស្ងប់សង្រ្គាមអត់មានអីទេ អីចឹងគាត់ក៏មកបួសនៅវត្ត ។

ដានីៈ	វត្តអីគេ?

សាម៉េតៈ	វត្តត្រពាំងប្រាសាទ ។

ដានី៖ គាត់មកពីខាងក្នុង?

សាម៉េត៖ បាទ!

ដានី៖ គាត់មកតាមកូន? មកឃើញកូននៅជាមួយកូន ហើយបួសនៅក្នុងវត្ត ។

សាម៉េត៖ កសាងព្រះពុទ្ធសាសនា ។

ដានី៖ ដល់ពេលក្រោយៗមកទៀត មានតែមួយអង្គហ្នឹង ឬក៏មាន?

សាម៉េត៖ មកជាបន្តៗរហូត ។ ហើយខាងក្នុងខ្លះ នេះខ្លះទៅបូកផ្សំគ្នា ។

ដានី៖ ខាងក្នុងមកបន្តទៅ ខាងកូនចៅអ្នកស្រុកអ្នកភូមិ យើងអតីតហ្នឹងក៏គាត់បួសមួយចំនួនទៀត?

សាម៉េត៖ បាទ!

ដានី៖ ទាក់ទងរឿងដូចថាវត្ត ព្រះសង្ឃ ប្រជាជនទៅវត្តសស្រាក់សស្រាំដែរ?

សាម៉េត៖ បាទ! ទៅ ។

ដានី៖ អ៊ំយើងបែកពីស្រុកប៉ុន្មានឆ្នាំ បានយើងចាប់ផ្តើមចូលទៅលេងស្រុកលើកទី១?

សាម៉េត៖ បើគិតតាំងពីនោះមកដល់នេះប្រហែលជា៤០ឆ្នាំ ។

ដានី៖ ៤០ឆ្នាំ បានមកលេងស្រុកវិញ?

សាម៉េត៖ បាទ! ក្រោយពីយើងផ្សះផ្សាហើយ ។

ដានី៖ ខុសប្លែកយ៉ាងម៉េចដែល ពេលដែលយើងបែកពីស្រុកមកយូរ ហើយពីក្មេងពេលមានសង្គ្រាមយើងចេញពីស្រុក ហើយដល់ពេលយើងបានសន្តិភាព យើងផ្សះផ្សាហើយត្រឡប់ទៅលេងស្រុក មានការប្លែកយ៉ាងម៉េចដែរ ស្រុកកំណើត?

សាម៉េត៖ ទៅដល់ស្រុកកំណើតរកផ្ទះអត់ឃើញ ។

ដានី៖ ពេលអ៊ំទៅស្រុកកំណើតបានជួបពីណាខ្លះ? ដូចថាកាលពីមុនឪពុកម្តាយបងប្អូននៅស្រុកកំណើតជាមួយគ្នា ដល់ពេលយើងចេញមកឆ្ងាយ ដល់ពេលត្រឡប់ទៅវិញបាត់បង់យ៉ាងម៉េចខ្លះ ឬនៅជួបជុំវិញទាំងអស់?

សាម៉េត៖ ភាគច្រើនវ័យស្រករខ្ញុំ ទី១ ស្លាប់ក្នុងសង្គ្រាមអាមេរិក ទី២ រោគាខ្លះទៅ ភាគតិចទេដែលនៅ វ័យស្រករខ្ញុំនៅសល់តិច ។ ដល់ទៅនៅសល់មួយៗបានគេដំណាលថាកូនមេភូមិ ពីមុនចេះ ក្រោយមកចេះ ដូចថាភូមិវាប្រែប្រួល ។ ខ្លះកូនក្មួយអីបើគេអត់ប្រាប់អត់ស្គាល់ទេ ហាក់ដូចជា មិននិយាយថាភ្លេចស្រុកកំណើតខ្លួនឯង ហាក់ដូចជាចង់វង្វេង ។

ដានី៖ ពីខួរក្បាល?

សាម៉េត៖ បាទ!

ដានីៈ ពីមុនយើងនឹកនា យើងគិតជាប់ គិតទៅវាទៅជាប់ក្នុងខួរក្បាលយើង ដល់ពេលបែកយូរទៅហាក់ដូចជារសាយបាត់ វាមិនសូវនឹកនា ដូចភ្លេច ។ ពេលអ៊ំទៅដល់ម្ដាយអ៊ំនៅទេ?

សាម៉េតៈ អត់ទេ អត់មាន ស្លាប់បាត់អស់ហើយ ។

ដានីៈ បងប្អូនអត់មានដែរ?

សាម៉េតៈ បងប្អូនអត់មានដែរ នៅតែក្មួយៗ បងប្អូនទៅនៅបាត់ដំបង ហាក់ដូចជាអស់ ។

ដានីៈ អ៊ំទៅប៉ុន្មានដងដែរ ទៅស្រុកកំណើត?

សាម៉េតៈ ទៅម្ដង ។

ដានីៈ ក្រោយមកអត់ដែលទៅទៀតទេ?

សាម៉េតៈ អត់ដែលទៅ ។

ដានីៈ បងប្អូនអ៊ំដែលថានៅបាត់ដំបងហ្នឹង អ៊ំចាប់ផ្ដើមទាក់ទងគាត់ជាប់រហូតតាំងពីក្មេង ឬទាល់តែពេលណា?

សាម៉េតៈ ទាល់តែស្រុកផ្សះផ្សា ចង់និយាយថាយើងផ្សះផ្សា៩៨ហ្នឹង បានទៅជួបគ្នាដឹងដំណឹងថានៅបាត់ដំបងបានទៅលេងតែម្ដង ។

ដានីៈ ឥឡូវខស្រាប់ទាក់ទងគ្នាដែរ?

សាម៉េតៈ អត់បានទាក់ទងទេ តាមខ្ញុំសន្និដ្ឋានបងស្រីហ្នឹងគាត់អាយុប្រហែលជាចិតសិបជាងហើយមិនថាម៉េចទេ ប្រហែលស្លាប់បាត់ក៏មិនដឹង ។

ដានីៈ អត់សូវបានទាក់ទងគ្នាទេ ។

សាម៉េតៈ អត់បានទាក់ទងគ្នា ។

ដានីៈ អីចឹងក្រុមគ្រួសារអ៊ំដូចអត់សូវជាប់លាប់ទាក់ទងគ្នាដឹងអី?

សាម៉េតៈ ព្រោះបែកគ្នា ។

ដានីៈ តាមទូរស័ព្ទអត់ដែរ?

សាម៉េតៈ ខាងនោះគេច្រើនតែដូរលេខទូរស័ព្ទពេក ដល់អីចឹងខ្ញុំក៏លំបាក ។

ដានីៈ មួយទៀត សំនួរចុងក្រោយ ទាក់ទងពីយើងនៅក្នុងតំបន់នេះវិញ ការពីមិនទាន់សមាហរណកម្មយើងនៅលើភ្នំ យើងនៅតស៊ូ ឧបមាថាយើងនៅអន្លក់ភាពជាមួយគ្នា យើងមានរបបហូបចុកដូចៗគ្នា ប្រហែលៗគ្នា កាលហ្នឹងយ៉ាងម៉េចដែរមានអារម្មណ៍ជិតស្និតជាមួយគ្នា ទោះជាយើងមកពីកន្លែងណាក៏ដោយ តែយើងនៅអន្លក់ភាព នៅតស៊ូជាមួយគ្នា មនោសញ្ចេតនាការរាប់អានគ្នាយ៉ាងម៉េច? ដល់ពេលបន្ទាប់ពីយើងសមាហរណកម្មហើយ យើងចាប់ផ្ដើមរស់នៅក្នុងភូមិ ក្នុងឃុំ យើងមានផ្ទះ មានដី ប្រកបរបររៀងៗ

ខ្លួន បានផលរៀងៗខ្លួន ។ អីចឹងការរាប់អានមនោសញ្ចេតនាវាងគ្នានិងគ្នាមានការខុសគ្នាម៉េចខ្លះដែរ កាលពីសម័យយើងតស៊ូ ហើយសម័យយើងសមាហរណកម្មហើយ?

សាម៉េតៈ សំរាប់ខ្លួនខ្ញុំ ពីមុនរស់នៅយ៉ាងណា ធ្លាប់ហូបចុកយ៉ាងណាក៏ដោយ ឯបច្ចុប្បន្ននេះទោះបីយើងមានជីវភាព ឬប្រកបការងាររចិញ្ចឹមជីវិតដោយឡែកៗពីគ្នាមែន តែអារម្មណ៍វានៅតែគិតគូរគ្នា នឹកអាឡៃ ជួយទុកធុរៈគ្នាទៅវិញទៅមក ។

ដានីៈ អត់អីទេ?

សាម៉េតៈ អត់មានអី ។

ដានីៈ មនោសញ្ចេតនា ការរាប់អានគ្នានៅដដែល អត់មានការផ្លាស់ប្តូរ?

សាម៉េតៈ បាទ! ពីព្រោះបើគិតពីរឿងដើមកំណើតដូចស្រុកទេស ដូចជាភូមិកំណើតវាឆ្ងាយៗដាច់ពីគ្នា តែមកនៅជាមួយគ្នាហាក់ដូចជាបងប្អូនបង្កើត ។

ដានីៈ មិនមានការខុសគ្នាអីទេ?

សាម៉េតៈ អត់ទេ ។

ដានីៈ អ៊ំទស្សប្រាហ៍អញ្ជើញទៅវត្តទេ?

សាម៉េតៈ វត្តនៅក្បែរផ្ទះ ថ្ងៃនេះត្រូវទៅវត្តតែអត់បានទៅ ។

ដានីៈ ទៅវត្តក្នុងពិធីអីគេ?

សាម៉េតៈ ថ្ងៃសីល ។

ដានីៈ ថ្ងៃសីលត្រូវទៅវត្ត?

សាម៉េតៈ បាទ!

ដានីៈ អ៊ំថ្ងៃសីលត្រូវទៅវត្ត?

សាម៉េតៈ បាទ!

ដានីៈ អ៊ំសុំសីលអីចឹង?

សាម៉េតៈ ថាសុំក៏ថាបាន គ្រាន់តែយើងមិនទាន់ចេះធម៌អីច្បាស់ ។

ដានីៈ អីចឹងភាគច្រើនទៅវត្ត?

សាម៉េតៈ បាទ!

ដានីៈ ទស្សប្រាហ៍ទៅវត្តដែរ?

សាម៉េតៈ ទៅរាល់ពេលសីល ។

ដានីៈ យើងទៅជួបជុំចាស់ៗ!

សាម៉េតៈ សំណេះសំណាលរឿងបុណ្យទាន សំណេះសំណាលរឿងជីវភាពអីខ្លះទៅ ។

ដានី:	ខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំអ៊ំទៀតហើយ រំខានអ៊ំយូរដែរជិត២ម៉ោង ។ អ៊ីចឹងអ៊ំមានអីបន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរ ។

សាម៉េត:	ដូចជាអស់ហើយ ព្រោះខ្ញុំបានបញ្ជាក់អស់ហើយ និយាយពីចុងក្រោយ និយាយពីក្នុងរបបបច្ចុប្បន្នដូចជាមិនមានអី ព្រោះខ្ញុំយល់ថាការឆ្លងកាត់ក្នុងប៉ុន្មានរបបហ្នឹង ហើយខ្ញុំបញ្ជាក់ចុងក្រោយថាដូចជាមិនមានរបបណា ក្រៅពីរបបនេះ ដោយធ្វើការផ្សះផ្សាជាតិបង្រួបបង្រួមជាតិ ហើយអភិវឌ្ឍន៍ប្រទេសទៅបានទេតាមមើល ទស្សនៈរបស់ខ្ញុំ មានតែដំណើរដូចបច្ចុប្បន្ននេះទៅអនាគត ។

ដានី:	អ៊ីចឹងខ្ញុំអរគុណអ៊ំច្រើន ដែលចំណាយពេលសំណេះសំណាលជាមួយខ្ញុំជាង២ម៉ោង ។

សាម៉េត:	បាទ!

ដានី:	អរគុណច្រើន ។

ចប់